# ”ខ្ញុំមិនដែលគិតថា រឿងនេះអាចកើតឡើងចំពោះក្មេងប្រុសសោះ”

អំពើរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទក្មេងប្រុសនៅកម្ពុជា

ការស្រាវជ្រាវស៊ើបរាវរក ខែមករា ឆ្នាំ២០០៨



ជំហានដំបូង
first step

# "ខ្ញុំមិនដែលគិតថារឿងនេះអាចកើតឡើងចំពោះក្មេងប្រុសសោះ"

ជំហានដំបូង
first step

**"I thought it could never happen to boys"**
**Research Summary - Khmer**

**សេចក្តីផ្តើម:**

នៅប្រទេសកម្ពុជា ការយល់ដឹងអំពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើក្មេងប្រុស នៅមានចំនួនតិចតួចនៅឡើយ (ការយល់ដឹងពីបញ្ហានេះកំពុងតែបន្តីកដុះដាល) ។ ដូចច្នេះ នេះគឺជាការសិក្សាស្រាវ ជ្រាវដំបូង ដែលបង្ហាញពីបញ្ហានេះយ៉ាងជាក់លាក់ ហើយដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះទទួលការឧបត្ថមថវិការពីអង្គការទស្សនៈពិភពលោករបស់ប្រទេសកាណាដា ហើយទទួលបំពេញបេសកម្មដោយអង្គការហាកា និងអនុវត្តការស្រាវជ្រាវដោយក្រុមអ្នកស្រាវជ្រាវ ដែលមានទីតាំង នៅអង្គការសេវាសង្គមកិច្ចកម្ពុជា (សសក) ។

នៅប្រទេសអភិវឌ្ឍន៍ ការយល់ដឹងពីការរំលោភបំពានភេទលើក្មេងប្រុស នៅមានលក្ខណៈលាក់កំបាំង រហូតដល់ប្រហែល១៥ឆ្នាំចុងក្រោយ ឬលើសពីនេះ ដែលប្រធានបទនេះត្រូវបានទទួលការចាប់អារម្មណ៍ពីអ្នក ស្រាវជ្រាវ និងអ្នកអនុវត្តនានា។ ការសិក្សាស្រាវជ្រាវជាលក្ខណៈសាកល បាននិយាយថា ៣០% នៃក្មេងប្រុសដែលទទួលរងការរំលោភបំពានផ្លូវភេទ (តាមរូបភាពខ្លះៗ)នៅក្នុងជីវិតរបស់ពួកគេ ជាលទ្ធផល នឹងទទួលរងនូវបញ្ហា/ផលប៉ះពាល់ដែលមានលក្ខណៈយូរអង្វែង រួមមានសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់ពួកគេ។ ការសិក្សាស្រាវជ្រាវនេះធ្វើឡើងនៅទីតាំងបីកន្លែងក្នុងប្រទេសកម្ពុជា គឺទីក្រុងភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង។ ការសិក្សានេះប្រព្រឹត្តឡើងបានដោយសារការស្តាប់ក្មេងប្រុស បុរសវ័យក្មេង បុគ្គលិកអាជីពបុគ្គលិកសង្គមកិច្ច មេធាវី បុគ្គលិកដែលធ្វើការទាក់ទងនឹងការការពារកុមារ និង ប្រធានអង្គការក្រៅរដ្ឋាភិបាល នានាក្នុងក្តីសង្ឃឹមសែវងយល់អំពីថា តើក្មេងប្រុសត្រូវបានគេរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទដូចម្តេច ហើយតើមានផលប៉ះពាល់អ្វីខ្លះចំពោះក្មេងប្រុសទាំងនោះ។

គោលបំណងមួយភាគធំនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីជួយអោយក្មេងប្រុសបានបញ្ចេញមតិ ចែករំលែក រឿងរ៉ាវ និងជួយពួកគេឱ្យបាននិយាយពីតំរូវការនៃសេវាជួយនានា ដូចជាការការពារ ការគាំទ្រពីអង្គការ គ្រួសារ សហគមន៍ និងរដ្ឋាភិបាល។

ការស្តាប់បុគ្គលិកនានាដែលធ្វើការជាមួយក្មេងប្រុស ជួយឱ្យក្រុមអ្នកស្រាវជ្រាវបានយល់ពីបទពិសោធន៍របស់បុគ្គលិក និងអ្នកអាជីពទាំងនោះ ហើយថែមទាំងជួយអោយយល់ពីបញ្ហានេះកាន់តែស៊ីជម្រៅ ព្រមទាំងអាចជួយឱ្យពួកគាត់កំណត់បាននូវតំរូវការរបស់បុគ្គលិកដែលត្រូវការការគាំទ្រ និងវគ្គបណ្តុះបណ្តាលបន្ថែម។ សង្ឃឹមថារបាយការណ៍នេះ នឹងជួយបង្កើនការយល់ដឹងអំពីបញ្ហានេះជាបន្ថែមទៀត ហើយនឹងនាំឆ្ពោះទៅរកបំលាស់ប្តូរវិជ្ជមានជាយូរអង្វែងនៅក្នុងការរស់នៅរបស់ក្មេងប្រុស និងបុរសវ័យក្មេង។

របាយការណ៍នេះ មានសំណូមពរនិងអនុសាសន៍នានា ដែលស្របទៅនឹងតំរូវការរបស់ក្មេងប្រុស បុគ្គលិក និងបុគ្គលិកអាជីពនានាដែលបំរើសេវាកម្មនៅក្នុងផ្នែកនេះ។ សង្ឃឹមថារបាយការណ៍ច្បាប់ដើមនៃការស្រាវជ្រាវនេះ នឹងត្រូវបានបោះពុម្ពផ្សាយ ព្រមទាំងបកប្រែជាភាសាខ្មែរ ដោយអង្គការទស្សនៈពិភពលោក។ ទន្ទឹមនឹងនេះ គម្រោងជំហានដំបូង បានរៀបចំសេចក្តីសង្ខេបអំពី ចំនុចសំខាន់ៗ ដែលមានបកប្រែជាភាសាខ្មែរ

សម្រាប់ចែកចាយជាព័ត៌មាន។ សេចក្ដីផ្ដើមនេះគួរតែអានដោយ ភ្ជាប់ជាមួយនឹងសេចក្ដីសង្ខេបនៃរបាយការណ៍ច្បាប់ដើមដែលមានបកប្រែជាភាសាខ្មែរ។

អាឡាស្ទែរ ហ៊ីលតុន
មករា ២០០៨

## ក្រុមអ្នកស្រាវជ្រាវ និងការរៀបចំការស្រាវជ្រាវ

ក្រុមអ្នកស្រាវជ្រាវមានគ្នាទាំងអស់ចំនួន ៥នាក់។ ពួកគាត់ភាគច្រើនមានបទពិសោធន៍ក្នុងធ្វើការស្រាវ ជ្រាវ និងការងារសង្គមកិច្ចនៅតាមផ្នែកផ្សេងៗ។ ក្រុមអ្នកស្រាវជ្រាវរួមមានមាន គង់ សុខេម, សឹង សុធារត្ន័, អ៊ុង សុផាត, សុខ ចន្នី, និង នង សុជាតិ។ ក្រុមត្រូវបានគាំទ្រដោយជំនួយការផ្នែករដ្ឋបាល ឈ្មោះ តេង ប៉ុណ្ណារី និងអ្នកបកប្រែ ឡុង វិបុល។ នៅជិតចុងបញ្ចប់នៃការស្រាវជ្រាវ ម៉េង ដាលីន បានចូលរួមជួយ ក្នុងការសិក្សាស្រាវជ្រាវនេះផងដែរ តាមរយៈការជួយសម្ភាសន៍បុគ្គលិក (ពេញវ័យ) ៣ ឬ៤នាក់។ ចំណែកឯ ទីប្រឹក្សានិងជាប្រធានគម្រោងនេះគឺ អាឡាស្ទ័រ ហ៊ីលតុន។

ការអភិវឌ្ឍន៍ការកសាងសមត្ថភាពរបស់អ្នកស្រាវជ្រាវគឺជាគន្លឹះដ៏សំខាន់ដែលនាំឱ្យគម្រោងនេះទទួល បានជោគជ័យ។ គោលបំណងនៃការស្រាវជ្រាវនេះ គឺឱ្យក្រុមអ្នកស្រាវជ្រាវបានចូលរួមដំណើរការនៃការ ស្រាវជ្រាវនេះតាំងពីពេលចាប់ផ្ដើមដើមរហូតដល់ពេលឡើងបង្ហាញលទ្ធផល។ ការធ្វើបែបនេះមិនមែនត្រឹមតែ បង្កើនគុណភាពទិន្នន័យប៉ុណ្ណោះទេ តែថែមទាំងជួយបង្កើនជំនឿជាក់ និងជំនាញដល់ក្រុមអ្នកស្រាវជ្រាវទៀតផង (ការឈរពីក្រោយដើម្បីគាំទ្រសមាជិកក្រុមម្នាក់ៗធ្វើអោយដំណើរការនៃការស្រាវជ្រាវនេះអភិវឌ្ឍទៅមុខ)។ ដូចច្នោះហើយទើប២ខែមុនពេលចាប់ផ្ដើមការសិក្សាស្រាវជ្រាវនេះ សមាជិកក្រុមត្រូវបានបណ្ដុះបណ្ដាលដើម្បី រៀបចំរបៀបនៃការអនុវត្តន៍កិច្ចការនេះ។ ជាការចាំបាច់ដែលត្រូវកត់សំគាល់ថា ក្រមសីលធម៌ដែលទាក់ទងនឹង សុវត្ថិភាព និងការរក្សាការសម្ងាត់របស់អ្នកចូលរួមសម្ភាសន៍ទាំងអស់ត្រូវបានប្រើជាគោលការណ៍សម្រាប់អនុវត្ត នៅក្នុងគម្រោងនេះ។

## ការជ្រើសរើសអ្នកចូលរួមនិងវិធីសាស្ត្រ

មុនពេលចាប់ផ្ដើមការស្រាវជ្រាវ បុគ្គលសំខាន់ៗចំនួន ២៣នាក់ត្រូវបានសម្ភាសន៍ និងជួបពិភាក្សា។ បុគ្គលទាំងនោះមានបទពិសោធន៍ធ្វើការខាងផ្នែកសុខុមាលភាពសង្គមដែលរួមមានអ្នកស្រាវជ្រាវ គ្រូបណ្ដុះបណ្ដាល ទីប្រឹក្សា និងប្រធានអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការជាមួយកុមារដែលត្រូវគេរំលោភបំពានផ្លូវភេទ។ ការជួបជាមួយពួកគាត់ទាំងនោះ ជួយឱ្យអាចកំណត់បានថា តើបុគ្គលនិមួយៗ និងអង្គការនានាមានឆន្ទៈកម្រិត ណាក្នុងការចូលរួមការសិក្សាស្រាវជ្រាវ ចូលរួមចំណែកអភិវឌ្ឍន៍ការជ្រើសរើសអ្នកចូលរួម កំណត់ចំនុចនិងសំនួរ សំខាន់ៗនានា និងជួយបង្កើតវិធីសាស្ត្រ។ ទីតាំងត្រូវបានជ្រើសរើសដើម្បីជាការឆ្លុះបញ្ចាំងពីតំបន់ផ្សេងៗ- ដូចជាតំបន់ទីក្រុង (ភ្នំពេញ) តំបន់ទេសចរណ៍ (ខេត្តព្រះសីហនុ) និងតំបន់ជនបទ (ខេត្តបាត់ដំបង)។

ការសិក្សាស្រាវជ្រាវនេះបានកំណត់ថា ការជ្រើសរើសអ្នកចូលរួម (បើអាចទៅរួច) គួរតែជ្រើសរើស ក្មេងប្រុស ដែលជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ ឬក្មេងប្រុស ដែលរួចផុតពីការរំលោភបំពានផ្លូវភេទ ហើយកំពុងតែទទួលការថែទាំ ឬមានទំនាក់ទំនងជាមួយអង្គការនានា។ តាមរយៈការកសាងចំណងទំនាក់ទំនង

បន្តិចម្តងៗជាមួយអង្គការដែលធ្វើការជាមួយក្មេងប្រុស សំណាកដែលជាក្មេងប្រុស និងជាបុគ្គលិកដែលស្ម័គ្រចិត្តចូលរួមក្នុងបទសម្ភាសន៍ ត្រូវបានជ្រើសរើស។ ដើម្បីស្វែងយល់ពីបទពិសោធន៍របស់អ្នកចូលរួម បទសម្ភាសន៍ត្រូវបានរៀបចំធ្វើឡើងជាមួយអ្នកដែលមានតួនាទីខុសៗគ្នាតាមដែលអាចដូចជា: អ្នកអាជីព អ្នកពិគ្រោះបញ្ហា បុគ្គលិកសង្គមកិច្ច អ្នកចិត្តវិទ្យា ព្រះសង្ឃពុទ្ធសាសនា ប្រធានក្រុម អ្នកសម្របសម្រួលគម្រោង មេធាវី និងរហូតដល់ទៅប្រធានអង្គការក្នុងនិងក្រៅស្រុក។

## វិធីសាស្រ្តនៃការស្រាវជ្រាវ

វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យគឺមួយភាគធំតាមបែបគុណភាព។ ការសម្ភាសន៍តាមបែប ពាក់កណ្តាលរចនាសម្ព័ន្ធ (ផ្តល់ពេលអោយអ្នកចូលរួមនិយាយដោយមានសំនួរបើកភាគច្រើន) ត្រូវបានរៀបចំ ដោយក្រុម។ ប្រធានបទដែលងាយប៉ះពាល់អារម្មណ៍ អាយុ សមត្ថភាព និងបទពិសោធន៍របស់អ្នកចូលរួម សម្ភាសន៍ត្រូវបានប្រើដោយមានលក្ខណៈបត់បែន រួមជាមួយនឹងការប្រើវិធីសាស្រ្តផ្សេងៗដើម្បីប្រមូលទិន្នន័យ។ យើងពិចារណាឃើញថា ការពិភាក្សាពីបទពិសោធន៍រំលោភបំពានផ្លូវភេទនេះ គឺជាប្រធានបទដែលពិបាកនិយាយដូចច្នេះហើយ ទើបសកម្មភាព និងឧបករណ៍ផ្សេងៗត្រូវបានប្រើក្នុងការជួយកសាងចំណងទំនាក់ទំនង ព្រមទាំងជួយអោយក្មេងប្រុសនិយាយពីបទពិសោធន៍របស់ពួកគេតាមបែបផ្សេងៗ។ វិធីសាស្ត្រមួយចំនួនត្រូវបានប្រើ ដូចជាការពិភាក្សា ការគូររូប ឬការសរសេរ ដើម្បីជួយអោយក្មេងប្រុសនិយាយចេញពីរឿងរ៉ាវដែលបានកើតឡើង និងគំនិតផ្សេងៗរបស់ពួកគេ។ លោកអ្នកអាចអានព័ត៌មានលំអិតអំពីកាលវិភាគនៃការសម្ភាសន៍ នៅក្នុងរបាយការណ៍ការស្រាវជ្រាវពេញលេញ។

## ចំនុចសំខាន់ៗដែលការសិក្សាស្រាវជ្រាវចង់ស្វែងយល់អំពីពីក្មេងប្រុសមានដូចតទៅ:

- តើពួកគេទទួលរងបទពិសោធន៍នៃការរំលោភបំពាន និងគេងប្រវ័ញ្ចផ្លូវភេទដោយរបៀបណា?
- តើនរណាដែលជាអ្នកទទួលខុសត្រូវចំពោះរឿងនេះ ហើយតើស្ថានការណ៍ទាំងនោះកើតឡើងដោយរបៀបណា?
- តើវាប៉ះពាល់ដល់ក្មេងប្រុសដោយរបៀបណា?
- តើបទពិសោធន៍របស់ក្មេងប្រុសក្នុងការទទួលជំនួយមានលក្ខណៈដូចម្តេច?
- តើពួកគេមានគំនិតអ្វីខ្លះទាក់ទងនឹងវិធីសាស្ត្រដែលក្មេងប្រុសគួរតែត្រូវបានជួយ គាំទ្រ និងការពារពីសំណាក់ឳពុកម្តាយ អ្នកថែទាំ និងបុគ្គលិកអង្គការ និងអ្នកផ្សេងៗទៀត?
- តើពួកគេអាចមានមតិអ្វីចង់ផ្តាំផ្ញើរដល់អ្នកដទៃ ទាក់ទងនឹងការរំលោភលើក្មេងប្រុស?

**ចំនុចសំខាន់ៗបន្ទាប់ពីបានជួបជាមួយបុគ្គលិក និងអ្នកចូលរួម (ពេញវ័យ) មានដូចតទៅៈ**

- តើចំណេះដឹង និងការយល់ដឹងរបស់ពួកគេពីបញ្ហានេះមានកម្រិតណា ហើយតើពួកគេមានឥរិយាបទយ៉ាងណាចំពោះក្មេងប្រុសដែលត្រូវគេរំលោភបំពានផ្លូវភេទ?
- តើពួកគេមានបទពិសោធន៍ និងគំនិតអ្វីខ្លះក្នុងការជួយក្មេងប្រុស?
- ក្នុងការជួយគាំទ្រក្មេងប្រុស តើពួកគេជួបប្រទះភាពងាយស្រួល និងភាពលំបាកអ្វីខ្លះ?
- តើពួកគេត្រូវការការវគ្គបណ្តុះបណ្តាល និងការគាំទ្រអ្វីខ្លះ?

គោលការណ៍ក្រមសីលធម៌ម៉ត់ចត់ និងការស្ម័គ្រចិត្តក្នុងការចូលរួមសម្ភាសន៍ត្រូវបានប្រើតាំងពីដើមរហូតដល់ចប់។ អ្នកចូលរួមអាចជ្រើសរើសមិនឆ្លើយសំនួរ រឺឈប់ពីការសម្ភាសន៍បានគ្រប់ពេលដោយមិនទទួលសម្ពាធអ្វីទាំងអស់។ ការសម្ភាសន៍ទាំងអស់ជាមួយក្មេងប្រុស ធ្វើឡើងដោយអ្នកស្រាវជ្រាវជនជាតិខ្មែរ។

ប្រធានក្រុមនៃការស្រាវជ្រាវគឺជាអ្នកសម្ភាសន៍បុគ្គលិក (ដែលជាអ្នកចូលរួម) មួយភាគធំ ដោយប្រើអ្នកបកប្រែពេលណាចាំបាច់។ ការសម្ភាសន៍ក្រុមគោលដៅ៣ឬ៤ក្រុមគឺត្រូវសម្ភាសន៍ជាមួយមនុស្សពេញវ័យ។ ទិន្និន័យផ្សេងទៀតត្រូវបានប្រមូលតាមរយៈប្រពន្ធ័ផ្សព្វផ្សាយ និងសារព័តិមាន។ លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះក៏បានប្រើ ការធ្វើវិវេចនាឯកសារផ្សេងៗ (literature review) ការស្រាវជ្រាវរបស់អ្នកប្រាជ្ញនានាទាំងនៅក្នុងនិងក្រៅប្រទេសដែលទាក់ទងនឹងប្រធានបទនេះ (ការសង្ខេបពីការស្រាវជ្រាវនេះអាចស្វែងយល់បន្ថែមទៀត នៅក្នុងរបាយការណ៏ចុងក្រោយ)។

ជាសរុប ការស្រាជ្រាវនេះ គឺយើងខ្ញុំធ្វើបទសម្ភាសន៍ (ដោយស្តាប់) ក្មេងប្រុស និងបុរសវ័យក្មេងចំនួន ៤០នាក់ នៅបីខេត្ត-ក្រុង។ ចំនួនសរុបមនុស្សពេញវ័យដែលចូលរួមក្នុងការស្រាវជ្រាវនេះ (ទាំងការសម្ភាសន៍ម្នាក់ទល់ម្នាក់ ឬជាក្រុម) កើនឡើងរហូតដល់ទៅ ២០០នាក់។

ការស្រាវជ្រាវដែលចុះទៅសម្ភាសន៍ផ្ទាល់មានរយៈពេលពីខែមេសា រហូតដល់ខែមិថុនា ឆ្នាំ២០០៧។

**ចំនុចសំខាន់ៗដែលបានរកឃើញនៅក្នុងការស្រាវជ្រាវនេះ**

របាយការណ៏ពេញលេញនេះ បានបញ្ចូលនូវការប្រៀបធៀប និងពិភាក្សាលំអិតលើលទ្ធផលសម្ភាសន៍នៅក្នុងខេត្ត-ក្រុងចំនួនបី។ ឯកសារដែលចែកជូននេះគ្រាន់តែបង្ហាញពីចំនុចសំខាន់ខ្លះៗនៃលទ្ធផលនេះតែប៉ុណ្ណោះ ។

**តើនរណាជាអ្នករំលោភបំពាន?**

មនុស្សពេញវ័យជាច្រើន ជឿថាជនបរទេស ឬ បុរសដែលរួមភេទដូចគ្នាគឺជាអ្នករំលោភបំពាន ហើយបញ្ហានេះនៅតែបន្តកើតឡើងនាពេលថ្មីៗនេះ។ តែការសិក្សាស្រាវជ្រាវនេះមិនយល់ស្របជាមួយនឹងទស្សនៈនេះឡើយ ពីព្រោះការស្រាវជ្រាវនេះបានរកឃើញថា ក្មេងប្រុសមួយភាគធំដែលទទួលរងការរំលោភបំពានពីមនុស្សធំពេញវ័យដែលមានទាំងជនជាតិខ្មែរ និងបរទេស តាមស្ថានភាពផ្សេងៗមានជាយូរយារណាស់មកហើយ។ ក្មេងប្រុស

ក៏ទទួលរងការរំលោភបំពានពីក្មេងប្រុសដូចគ្នា មនុស្សវ័យជំទង់ និងមានករណីខ្លះគឺក្មេងប្រុសក៏ទទួលរងការរំលោភបំពានពីស្ត្រីផងដែរ។ អ្នកដែលរំលោភបំពាន អាចជាអ្នកជិតខាង សមាជិកគ្រួសារ និងអ្នកដទៃផ្សេងទៀតដែលក្មេងប្រុសជឿទុកចិត្ត។

## ការមិនរាយការណ៍ពីអ្វីដែលកើតឡើង

ដោយសារឥទ្ធិពលនៃជំនឿបានធ្វើអោយបញ្ហានេះត្រូវលាក់បាំង មិនរាយការណ៍ ហើយព្យាយាមធ្វើអោយរឿងនេះទៅជារឿងតូចតាច។ អ្នកខ្លះភ្ជាប់បញ្ហានេះជាមួយនឹងជំនឿនៃវប្បធម៌ដែលទាក់ទងនឹងអត្តសញ្ញាណក្នុងនាមជាបុរសទាក់ទងនឹងអ្វីជាភេទ និងអ្វីជាការរំលោភភេទ។ ពួកគេច្រើនភ្ជាប់បញ្ហានេះទៅនឹងជំនឿ តែពួកគេមិនបានគិតថា ការរំលោភបំពានផ្លូវភេទលើក្មេងប្រុស គឺជាការប្រឆាំងនឹងវប្បធម៌ខ្មែរ ហើយនេះជាបញ្ហាមួយដែលគួរយកចិត្តទុកដាក់។ ការជឿបែបនេះកម្រកើតឡើង ហើយបើទោះជាកើតឡើង ក៏គេគិតថាវាជារឿងតូចតាច គេគិតថាវាមិនមែនជាការរំលោភបំពាន ឬវាមិនធ្វើអោយប៉ះពាល់អ្វីដល់ក្មេងប្រុស ឡើយ ព្រោះមានលុយជាថ្នូរ។ គេគិតថាវាមិនអាចទៅរួចទេដែលក្មេងប្រុស និងបុរសពេញវ័យមានទំនាក់ទំនង ផ្លូវភេទជាមួយគ្នា។ ប្រសិនបើក្មេងប្រុសត្រូវគេរំលោភ លុះណាតែក្មេងប្រុសចេញទឹកកាម។ ជាទូទៅ ការយល់ ដឹងពីការរំលោភ និងកេងប្រវ័ញ្ចផ្លូវភេទលើក្មេងប្រុសនៅមានលក្ខណៈតិចតួចណាស់។

ទន្ទឹមនឹងនេះ អ្នកចូលរួមក្នុងការសម្ភាសន៍ខ្លះជឿថាការរំលោភបំពានផ្លូវភេទលើក្មេងប្រុសអាចធ្វើឱ្យក្មេងប្រុសមានមានបញ្ហា តែអ្នកខ្លះមិនជឿថាការរំលោភបំពាននេះអាចបណ្តាលឱ្យប៉ះពាល់អ្វីធ្ងន់ធ្ងរដល់ក្មេងប្រុសឡើយ។ ព្រោះគេរំពឹងថាក្មេងប្រុសត្រូវតែជាអ្នកដែលអាចការពារខ្លួនឯងបាន និងអាចជាសះស្បើយភ្លាមៗ ដោយពួកគេជឿថាចំនុចសំខាន់នោះគឺ នៅត្រង់ព្រហ្មចារីយ៍ និងកិត្តិយសរបស់ក្មេងស្រីដែលអាចបាត់បង់ ចំពោះបទពិសោធន៍របស់ក្មេងប្រុសមិនមានអ្វីធ្ងន់ធ្ងរ និងមិនប៉ះពាល់ឡើយ។ តែការស្រាវជ្រាវបង្ហាញថាការជឿបែបនេះមិនមែនជាការពិតឡើយ។

## បទពិសោធន៍របស់ក្មេងប្រុស

### កត្តាប្រថុយប្រថាន-តើអ្វីខ្លះដែលនាំឱ្យមានការរំលោភ និងការកេងប្រវ័ញ្ចផ្លូវភេទកើតឡើងលើក្មេងប្រុស?

ចេញពីលទ្ធផលគំរូ យើងឃើញកត្តាប្រថុយប្រថានជាច្រើន ដែលនាំអោយមានការរំលោភ និងការកេងប្រវ័ញ្ចផ្លូវភេទលើក្មេងប្រុសកើតឡើង។ កត្តាទាំងនោះរួមមាន ការប្រឈមមុខនឹងភាពក្រីក្រ ឪពុកម្តាយលែងលះគ្នា ឬការស្លាប់របស់ឪពុកម្តាយ ឬ បងប្អូន និងអំពើហិង្សាក្នុងគ្រួសារ។ ក្មេងប្រុសខ្លះបានរៀបរាប់ពីការចាកចេញពីផ្ទះទៅរស់នៅតាមចិញ្ចើមថ្នល់តាំងពីខ្លួននៅក្មេង ដើម្បីគេចចេញពីអំពើហិង្សា និងរកលុយមកជួយគ្រួសាររបស់ពួកគេ។ ក្មេងប្រុសជាច្រើនមិនសូវបានទៅសាលារៀន។ ក្មេងប្រុសខ្លះនិយាយថាស្ថានភាពនៅក្នុងផ្ទះដែលមានតែការប្រើស្រា ឬថ្នាំញៀន បានក្លាយទៅជារឿងធម្មតាទៅហើយ។ នេះមិនមែនមានន័យថា មានតែក្មេង

ប្រុសដែលរស់ក្នុងជីវភាពក្រីក្រទៅដែលជួបប្រទះការរំលោភបំពានផ្លូវភេទនោះ ចំណែកឯក្មេងប្រុសដែលរស់នៅក្នុងគ្រួសារជីវភាពធូរធារមិនទទួលរងការរំលោភបំពានផ្លូវភេទនោះឡើយ ។ លទ្ធផលនៃការស្រាវជ្រាវនេះទទួលបានពីការសម្ភាសន៍អង្គការនានាដែលបំពេញការងារជាមួយក្មេងប្រុស ។

ក្មេងប្រុសបញ្ជាក់ថា ពួកគេមានចំណេះដឹងតិចតួចបំផុតទាក់ទងនឹងផ្លូវភេទមុនការរំលោភបំពានផ្លូវភេទកើតឡើង ហើយមួយភាគធំនៃក្មេងប្រុសមិនបានដឹងថា ការរំលោភបំពានផ្លូវភេទគឺចាប់ផ្តើមឡើងដោយការមានទំនាក់ទំនងបែបមិត្តភាពជាមួយមនុស្សធំពេញវ័យឡើយ ។

នៅពេលដែលគេដឹងថា ក្មេងប្រុសត្រូវគេរំលោភបំពានផ្លូវភេទ ក្មេងប្រុសទាំងនោះជារឿយៗត្រូវក្លាយទៅជាក្រុមគោលដៅដែលទទួលរងការរើសអើង មើលងាយ សើចចំអកពីសហគមន៍ ដែលជាហេតុនាំអោយពួកគេមានភាពឯកោ និងត្រូវគេដាក់ឱ្យនៅដាច់ដោយឡែកពីគេឯង ។ ភាពឯកោ រួមជាមួយកត្តាដទៃទៀតដូចជា កង្វះការគាំទ្រ ឬការរកប្រាក់ចំណូល និងភាពក្រីក្រ ជាលទ្ធផលធ្វើអោយក្មេងប្រុសកាន់តែងាយរងគ្រោះ ហើយរុញច្រានជីវិតរបស់ពួកគេឱ្យធ្លាក់ ចូលទៅក្នុងស្ថាន ភាពរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ។ នៅក្នុងករណីនេះគេបែរជាយល់ថា ក្មេងប្រុសមិនមែនជាជនរងគ្រោះ នោះទេ ព្រោះគេគិតថាក្មេងប្រុសបានយល់ព្រម ។

ក្មេងប្រុសត្រូវគេបង្ខំអោយចូលរួមក្នុងសកម្មភាពរំលោភបំពានផ្លូវភេទនានាដូចជា ការរួមភេទតាមមាត់ និងរន្ធគូទ ។ ភាគច្រើននៃការរួមភេទដោយដាក់បញ្ចូលលិង្គ គឺមិនបានប្រើស្រោមអនាម័យឡើយ ហើយមួយភាគធំនៃក្មេងប្រុសត្រូវទទួលរងរបួសនៅត្រង់ទ្វារលាមក ដូចជាការដាច់ និងរលាត់ ហើយភាគច្រើនមិនបានព្យាបាល ។

## ផលប៉ះពាល់នៃការរំលោភបំពានផ្លូវភេទ

ស្រដៀងគ្នាទៅនឹងលទ្ធផលនៃការស្រាវជ្រាវ និងមតិរបស់អ្នកស្រាវជ្រាវនៅលើសកលលោក ក្មេងប្រុសនៅក្នុងប្រទេសកម្ពុជាដែលទទួលរងបទពិសោធន៍នេះបានរៀបរាប់ពីបញ្ហា និងភាពលំបាកនានាដែលខ្លួនមាន ទាំងរយៈពេលខ្លីនិងវែង ។ ពួកគេរៀបរាប់ពីអារម្មណ៍សំខាន់ៗដូចជា ភាពអាម៉ាស់ ការបាត់បង់កិត្តិយស (ផ្ទុយពីជំនឿដែលមនុស្សជាច្រើនជឿ) ខ្លាចអ្នកដទៃដឹងពីការរំលោភបំពានផ្លូវភេទ អារម្មណ៍ច្របូកច្របល់ពីទំនាក់ទំនង ផ្លូវភេទ (ភេទនិងយេនឌ័រ) បន្ទោសខ្លួនឯង អារម្មណ៍ឯកោ និងខឹងខ្លួនឯង ។ ក្មេងប្រុសភាគច្រើន រៀបរាប់ពីបទពិសោធន៍ដែលទាក់ទងនឹងសុខភាពផ្លូវចិត្ត ដូចជាយល់សប្តិអាក្រក់ ចង់សម្លាប់ខ្លួន ការប្រើថ្នាំញៀន ដើម្បីបំភ្លេច និងលាក់បាំងការឈឺចាប់របស់ពួកគេ ។ បើនិយាយជារួម គឺការរំលោភបំពានផ្លូវភេទធ្វើឱ្យ ជីវិតរបស់ពួកគេក្រឡាប់ចាក់ ដែលធ្វើអោយអ្នកដែលរស់នៅជុំវិញក្មេងប្រុសមិនដឹងថាត្រូវជួយក្មេងប្រុសដោយ របៀបណា ។

នៅក្នុងការស្រាវជ្រាវ យើងបានជួបក្មេងប្រុស និងបុរសពេញវ័យដែលធ្លាប់មានបទពិសោធន៍នៃការរំលោភបំពានផ្លូវភេទតាំងពីកុមារភាព ហើយពួកគេមានអារម្មណ៍ឈឺចាប់នៅពេលដែលពួកគេត្រូវគេរំលោភបំពានផ្លូវភេទលើកដំបូង ។ នេះ បញ្ជាក់អោយឃើញថាមនុស្សប្រុសគ្រប់អាយុ ត្រូវការការគាំទ្រផ្លូវកាយ អារម្មណ៍ និងចិត្តរបស់ពួកគេ តាំងពីយូរណាស់មកហើយ ។

**ពីអ្នកដែលត្រូវគេរំលោភ ទៅជាអ្នករំលោភគេ?**

ការស្រាវជ្រាវនេះបានរកឃើញថា មានបុរសពេញវ័យជាច្រើនដែលរស់នៅជុំវិញក្មេងប្រុសជឿថា ក្មេងប្រុសដែលត្រូវគេរំលោភបំពានផ្លូវភេទភេទ នឹងក្លាយជាអ្នករំលោភបំពានផ្លូវភេទអ្នកដទៃ។ ចំនុចនេះ គឺជា "ទ្រឹស្តីអំពីវដ្តនៃការរំលោភ"។ ទស្សនៈនេះហាក់ដូចជាមានប្រជាប្រយិយភាព តែការស្រាវជ្រាវជាអន្តរជាតិបានបង្ហាញថា ជនរងគ្រោះដោយការរំលោភបំពានផ្លូវភេទមិនក្លាយទៅអ្នករំលោភទេ។ នៅប្រទេស កម្ពុជាគួរតែមានការស្រាវជ្រាវដើម្បីស្វែងយល់ពីបញ្ហានេះបន្ថែមទៀត (ពីអាកប្បកិរិយានៃការរំលោភបំពានផ្លូវភេទ)។ ចំនុចដែលទាក់ទងនឹងប្រធានបទនេះនឹងត្រូវបកស្រាយលំអិតពីជំនឿទាំងនេះ នៅក្នុងរបាយការណ៍ចុងក្រោយ។

**ក្មេងប្រុស និង ការថែទាំ (ចិញ្ចឹម) ក្មេងប្រុសនៅក្នុងវប្បធម៌ខ្មែរ**

នៅក្នុងការស្រាវជ្រាវនេះក៏នឹងមានលើកឡើងពីការប៉ះស្ទាប ឬថើបប្រដាប់ភេទរបស់ក្មេងប្រុសអាយុតិចជាង ៣ឆ្នាំ ដែលជាធម្មតាអ្នកថែទាំច្រើនតែធ្វើ។ គេតែងគិតថាការធ្វើដូចនេះគឺជាការបង្ហាញក្តីស្រឡាញ់ទៅក្មេង។ វាក៏ ជារឿងធម្មតាសំរាប់មនុស្សធំដែលលេងជាមួយក្មេងប្រុសធំៗដោយចាប់ស្រាតខោ ឬទាញប្រដាប់ភេទរបស់ក្មេងប្រុសនៅ មុខអ្នកដទៃ ។ នៅក្នុងចំណោមមនុស្សពេញវ័យ និងបុគ្គលិក គំនិតនេះគឺមាន លក្ខណៈច្របូកច្របល់ដោយខ្លះយល់ថាមិនមានផលប៉ះពាល់អ្វីទេ (ទៅតាមកម្រិតអាយុណាមួយ) ហើយខ្លះគិតថា វាអាចធ្វើអោយប៉ះពាល់ដល់ក្មេងប្រុសទៅថ្ងៃក្រោយ។ អ្វីដែលគួរកត់សំគាល់នោះ គឺក្មេងប្រុសឆ្លើយតបវិញថាពួកគេមិន ពេញចិត្តសោះនឹងការធ្វើបែបនេះដាក់ពួកគេ បើទោះជាទង្វើបែបនេះ ជាការបង្ហាញក្តីស្រឡាញ់ក៏ដោយ។ ការធ្វើ បែបនេះធ្វើអោយក្មេងប្រុសខ្មាស់គេ និងខឹង។

**មនុស្សប្រុសរួមភេទដូចគ្នាក៏ត្រូវគេរំលោភដូចជាកុមារា និងមនុស្សពេញវ័យដែរ**

ក្រុមអ្នកស្រាវជ្រាវបានជួបក្មេងប្រុស និងបុរសពេញវ័យ ៣ ឬបួននាក់ដែលគេកំណត់ថាពួកគាត់គឺជាមនុស្សប្រុសរួមភេទដូចគ្នា (MSM) ពួកគាត់និយាយថា ពួកគាត់ក៏ត្រូវគេរំលោភបំពានផ្លូវភេទកាលពីពួកគាត់នៅពីក្មេងដែរ ដោយជនជាតិខ្មែរដែលជាសមាជិកគ្រួសារ និងអ្នកនៅក្នុងសហគមន៍។ ខ្លះនិយាយពីបទពិសោធន៍ដែលត្រូវគេរំលោភបំពានផ្លូវភេទ និងមានទំនាក់ទំនងផ្លូវភេទពេលដែលពួកគាត់ពេញវ័យ ហើយសកម្មភាពទាំងនោះមានលក្ខណៈហិង្សាដែលអាចហៅ បានថា "ការរំលោភបូក"។

**តើការជួយបែបណាដែលក្មេងប្រុសនិយាយថាពួកគេចង់បាន?**

ការឆ្លើយតបរបស់ក្មេងប្រុសជាច្រើនពីតម្រូវការជាមូលដ្ឋានរបស់ពួកគេ គឺ សុវត្ថិភាពផ្លូវកាយនិងផ្លូវអារម្មណ៍ ការរក្សាការសម្ងាត់ ការមានគេទទួលស្គាល់ដោយមិនវិនិច្ឆ័យ និងទទួលយកដោយការយល់ចិត្ត និងគោរព។

តម្រូវការបន្ថែមទៀតដែលពួកគេនិយាយមានដូចជា ការការពារ ការស្រឡាញ់ និងភាពជាសមាជិក នៅក្នុងក្រុម។ ក្មេងប្រុសជាច្រើនសំណូមពរអោយមានការជួយដល់ការសិក្សា និងការងាររបស់ពួកគេ ឯខ្លះទៀតចង់ឱ្យសង្គមការពារក្មេងប្រុសអោយបានម៉ត់ចត់ ទទួលស្គាល់ថាពួកគេក៏ទទួលរងការឈឺចាប់ពេលមានការរំលោភ បំពានផ្លូវភេទ ហើយក៏មានអារម្មណ៍អាម៉ាស់ខ្លាំង និងបាត់បង់កិត្តិយសផងដែរ។

ក្មេងប្រុសជាច្រើនក៏បាននិយាយផងដែរ អំពីអ្វីដែលពួកគេមិនចង់បានពីអ្នកគាំទ្រ និងអ្នកថែទាំ (ទាំងនៅផ្ទះ និងនៅមណ្ឌល)។ ពួកគេចង់អោយអ្នកគាំទ្រ និងអ្នកថែទាំមានភាពទន់ភ្លន់ជាជាងស្រែកដាក់ពួកគេ ឬប្រើហិង្សាពេលពួកគេធ្វើអ្វីមួយខុស។ ពេលសួរពួកគេថា តើសារអ្វីខ្លះដែលពួកគេចង់ចែករំលែកអោយអ្នកដទៃដឹង ដូចជា ឪពុកម្តាយ បុគ្គលិក និង រដ្ឋាភិបាល ពួកគេឆ្លើយតបថា ចំនុចសំខាន់ៗគឺត្រូវការឱ្យគេជឿក្មេងប្រុស ជួយការពារក្មេងប្រុស កុំមើលងាយក្មេងប្រុស និងទទួលស្គាល់ថាពួកគេក៏ចេះឈឺចាប់ដែរ ហើយពួកគេមានការឈឺចាប់ដោយសារតែការរំលោភបំពានផ្លូវភេទ ។

## ការប្រៀបធៀបក្មេងប្រុសទៅតាមតំបន់នានា

យើងបានដកស្រង់លទ្ធផលនៃទិន្និន័យខ្លះទទួលបានពីក្មេងប្រុស បុរស និងកម្មវិធីដែលធ្វើការជាមួយបុរសដែលរួចផុតពីការរំលោភបំពានផ្លូវភេទនៅហុងកុង និងនៅចក្រភពអង់គ្លេស ដើម្បីប្រៀបធៀបគ្នា។ យើងបានរកឃើញថា ភាគច្រើនក្មេងប្រុសដែលមានប្រវត្តិវប្បធម៌ខុសៗគ្នា មានគំនិតនិងតម្រូវការចង់ឱ្យមានការជួយដូចគ្នា។ ចំនុច ដែលគួរចាប់អារម្មណ៍ខ្លាំងនោះគឺ ក្មេងប្រុសទាំងបីតំបន់និយាយថា ពួកគេត្រូវការសុវត្ថិភាព ការរក្សាការសម្ងាត់ ការយល់ចិត្ត ការជឿ និងមិនវិនិច្ឆ័យអ្វីដែលបានកើតឡើងលើពួកគេ។ ចំនុចលំអិតបន្ថែមទៀត អាច មើលនៅលទ្ធផល (របាយការណ៍) ពេញពេញ។

## សម្លេងរបស់ក្មេងប្រុស

ក្មេងប្រុសត្រូវបានសុំអោយបញ្ចេញយោបល់ពីអ្វីដែលពួកគេចង់និយាយទៅប្រជាជននៅក្នុងប្រទេស កម្ពុជា ដូចជាឪពុកម្តាយ អ្នកថែទាំ ក៏ដូចជាក្មេងប្រុសដទៃៗទៀត និងអ្នករំលោភបំពានផ្លូវភេទ។ របាយការណ៍ ពេញលេញ រៀបរាប់ពីមតិដែលក្មេងប្រុសទាំងបីតំបន់មាន។ ខាងក្រោមនេះគឺជាចំនុចខ្លះៗដែលពួកគេលើកឡើង:

- **ក្មេងប្រុសមិនអាចយំឡើយ ប្រសិនបើយើងយំ គេនឹងនិយាយថាយើងទន់ខ្សោយ ពួកគេមិនយល់ទាល់តែសោះថាតើយើងឈឺចាប់កម្រិតណា។**
- **ការគិតដែលថាការរំលោភបំពានផ្លូវភេទមិនកើតឡើងលើក្មេងប្រុស វាមិនមែនជាការពិតនោះទេ-ពីព្រោះវាពិត ជាកើតឡើងមែន!**
- **កុំស្តីបន្ទោសអោយខ្ញុំ.....សូមស្តាប់នូវអ្វីដែលខ្ញុំនិយាយ ហើយជឿខ្ញុំផង!**
- **ខ្ញុំមិនអាចបំភ្លេចអ្វីដែលកើតឡើងលើខ្ញុំសោះ។**

- **ខ្ញុំសោកសៅ និងមិនដឹងថានរណាដែលខ្ញុំអាចនិយាយជាមួយបាននោះទេ ព្រោះខ្ញុំខ្លាចសើច ចំអកដាក់ខ្ញុំ។**
- **ខ្ញុំស្អប់ទង្វើនេះណាស់ ហើយក៏មិនចូលចិត្តមនុស្សធំធ្វើដូចនេះដាក់ខ្ញុំដែរ ប៉ុន្តែខ្ញុំមិនហ៊ានប្រាប់គេទេ ព្រោះខ្ញុំអាម៉ាស់ខ្លាំង។**
- **អ្នកខ្លះនិយាយថាខ្ញុំមិនសូវយកចិត្តទុកដាក់លើការសិក្សា ដែលការពិតខ្ញុំមិនអាចសិក្សាបាន។ ខ្ញុំមិន ខ្ជិលទេ.......ខ្ញុំមិនចង់ប្រាប់ពួកគេពីបញ្ហាដែលខ្ញុំមាន ពីព្រោះខ្ញុំខ្លាចពួកគេរឹតតែបន្ទោសខ្ញុំថែម ទៀត។**
- **សូមកុំធ្វើអោយក្មេងប្រុសអាម៉ាស់ ឬមើលងាយលើក្មេងប្រុសដែលទទួលរងបទពិសោធន៏រំលោភ បំពានផ្លូវភេទ-សូមលើកទឹកចិត្ត ហើយលួងគ្នាផង!**
- អ្នកភូមិ: **ប្រសិនបើអ្នកដឹងពីស្ថានភាពរបស់ពួកយើង សូមរក្សាការសម្ងាត់ផង ដើម្បីពេលយើងធំ ឡើង យើងអាចនៅមានអនាគតនឹងគេ។**
- អ្នករំលោភបំពានផ្លូវភេទ: **សូមគោរពសិទិអ្នកដទៃផង-កុំរំលោភបំពានក្មេង!**
- **បើទោះជាកូនប្រុសដែលមានដើមទ្រូង៥ហត្ថ ក៏គ្នាចេះមានអារម្មណ៏ដែរ។**
- **កុំរំលោភគ្នាទៅវិញទៅមក ហើយកុំអោយរឿងនេះកើតឡើងតទៅទៀត។**

សាធារណៈជន អង្គការក្រៅរដ្ឋាភិបាល ឳពុកម្តាយ និងអ្នកថែទាំ: **កុំនិយាយដើមក្មេងប្រុស សូមលួងពួកគេ យកចិត្តទុកដាក់ចំពោះពួកគេ កុំរិះគន់ សូមជួយលើកទឹកចិត្តផង!**

ឳពុកម្តាយ: **កុំនិយាយថា មានតែក្មេងស្រីទេដែលជាជនរងគ្រោះនោះ ក្មេងប្រុសក៏ជាជនរងគ្រោះ ដែរ ដូចនេះត្រូវតែចេះប្រុងប្រយត្ន័ផង។ កុំឱ្យពួកគេចេញទៅក្រៅជាមួយអ្នកដទៃ ដោយគិតថា" វាជាក្មេងប្រុស" ។**

អ្នករំលោភបំពាន: **កុំធ្វើដូចនេះទៀតដាក់ក្មេងប្រុស! វាមិនល្អឡើយ វាបំផ្លាញអនាគតពួកយើង កុំសប្បាយចិត្ត លើគំនរទុក្ខរបស់អ្នកដទៃពេក។**

**ខ្ញុំអាម៉ាស់ណាស់ ខ្ញុំមិនចង់ជួបមិត្តភក្តិ និងមិនចង់និយាយជាមួយនរណាអោយបានច្រើនដូចពីមុន ឡើយ....ខ្ញុំខុសពីមុន ខ្ញុំមានអាកប្បកិរិយាប្លែក......ជូនកាលខ្ញុំកាច....ជូនកាលខ្ញុំចង់សំលាប់ខ្លួន។ អ្នកខ្លះមើលងាយខ្ញុំ ដោយនិយាយថា "ឯងជាប្រុសមិនគួរណាមានទំនាក់ទំនងភេទជាមួយភេទដូច គ្នានោះទេ" ពេលអនាគត បើខ្ញុំរៀបការ ហើយប្រពន្ធរបស់ខ្ញុំដឹង នាងនឹងមើលងាយខ្ញុំ។ ដូចនេះ តើខ្ញុំចង់បានអ្វីពីអ្នកដទៃ? ខ្ញុំចង់ឱ្យអ្នកនៅជុំវិញខ្ញុំ លើកទឹកចិត្ត និងលួងខ្ញុំ ហើយធ្វើឱ្យ ខ្ញុំសប្បាយចិត្ត....សូមមេត្តា.....កុំធ្វើអោយខ្ញុំអាម៉ាស់។**

**យើងត្រូវការការគាំទ្រពីគ្រួសារ (ឳពុកម្តាយ)-កុំបន្ទោសកូននូវអ្វីដែលកើតឡើង។**

**ក្មេងប្រុសជាច្រើនមិនដឹងថាទៅរកជំនួយពីណាទេ ហើយក៏មិនដឹងថាពួកគេមានបញ្ហានោះទេ។ ដូច នេះពួកគេមិនស្វែងរកជំនួយនោះទេ។ ក្មេងប្រុសមិនហ៊ាន ឬក្លាហានគ្រប់គ្រាន់ក្នុងការប្រាប់អ្នក**

**ដទៃពីការរំលោភបំពានផ្លូវភេទកើតឡើងឡើយ សូម្បីតែម្តាយខ្លួនឯងក៏ដោយ។ ក្មេងប្រុសអាចប្រាប់ពីការរំលោភបំពានផ្លូវភេទទៅមនុស្សណាម្នាក់ដែលគេជឿទុកចិត្ត។**

**យើងត្រូវការបុគ្គលិកដែលយល់ពីចិត្តយើង ហើយចេះអាណិតក្មេងប្រុស។ យើងមិនចូលចិត្តបុគ្គលិកណាដែលសំដីអាក្រក់ដាក់ក្មេងនោះទេ.....បុគ្គលិកគួរតែយល់ក្មេង កុំបន្ទោស ហើយត្រូវធ្វើដាក់ក្មេងដោយទន់ភ្លន់ផង។**

**មានកន្លែងដែលជួយអោយក្មេងប្រុស និងបុរសស្នាក់នៅ ដោយមានអ្នកពិគ្រោះបញ្ហា ដើម្បីជួយបញ្ហាសុខភាពផ្លូវចិត្ត និងពិភាក្សាអ្វីដែលពួកគេចង់ធ្វើ។ តែយើងក៏ត្រូវការរកការងារធ្វើ ដើម្បីជួយអោយយើងផ្តោតអារម្មណ៍ក្នុងការកសាងជីវិតរបស់យើងឡើងវិញដែរ។**

**បុគ្គលិកទាំងអស់ដែលធ្វើការជាមួយក្មេងប្រុស(ទោះជាស្រី ឬក៏ប្រុស) ត្រូវមានជំនាញពិគ្រោះបញ្ហា និងទន់ភ្លន់ ចិត្តល្អ និងរួសរាយរាក់ទាក់។**

**បុរសក៏ត្រូវការជួយដែរ!**

**កុំនិយាយដើមក្មេងប្រុស កុំរើសអើង និងមើលងាយពួកគេ។**

រដ្ឋាភិបាលៈ **សូមយកចិត្តទុកដាក់ និងការពារក្មេងប្រុស។**

**ខ្ញុំចង់អោយមនុស្សគ្រប់គ្នាដឹងថាក្មេងប្រុស និងបុរសដែលរួមភេទដូចគ្នាក៏ត្រូវគេរំលោភដែរ សូមជួយពួកគេផង និងជួយសង្គ្រោះពួកគេឱ្យដូចជាការជួយក្មេងស្រីផង។**

ក្មេងប្រុសៈ **សូមក្លាហានឡើង - ក្លាហានក្នុងការរាយការណ៍ទៅមនុស្សធំ ដូចជាឪពុកម្តាយ និងអង្គការ។ កុំលាក់រឿងនេះតទៅទៀត!**

ប៉ូលីស សហគមន៍ អាជ្ញាធរៈ **ជឿពីរបាយការណ៍ដែលជនរងគ្រោះរាយការណ៍ផង។ ពួកគេគួរតែទៅរៀន ដើម្បីស្វែងយល់ពីបញ្ហានេះ ដូចនេះពួកគេអាចមានលទ្ធភាពក្នុងការជួយក្មេងប្រុស។**

**ទិន្នន័យពីបុគ្គលិក និងអ្នកថែទាំ**

ទិន្នន័យដែលរៀបរាប់លំអិតពីទីតាំងទាំងបីនឹងមានរៀបរាប់នៅក្នុងរបាយការណ៍ចុងក្រោយ។ អ្វីដែលរៀបរាប់នាពេលនេះគឺគ្រាន់តែជាការសង្ខេបៈ

***ការយល់ដឹង***

បើប្រៀបធៀបគ្នារវាងទីតាំងនៅទីក្រុង និងតំបន់ទេសចរណ៍ ជាមួយទីតាំងនៅតំបន់ជនបទ យើងឃើញថាការយល់ដឹងពីបញ្ហានេះមានលក្ខណៈខុសគ្នាស្រឡះ។ នៅខេត្តបាត់ដំបង បើទោះជាមានបុគ្គលិកជាច្រើនដែលរាល់ថ្ងៃកំពុងធ្វើការជាមួយជនរងគ្រោះ ឬក្មេងប្រុសដែលរួចផុតពីការរំលោភបំពានផ្លូវភេទ ប៉ុន្តែមានតែបុគ្គលិក២ ឬ៣នាក់ប៉ុណ្ណោះដែលចាប់ផ្តើមបញ្ចេញមតិយោបល់ពីចំណេះដឹង និងការយល់ដឹងខ្លះៗរបស់ពួកគេទាក់ទងនឹងការ

រំលោភបំពានផ្លូវភេទលើក្មេងប្រុស។ ការខ្វះពតិមាន និងការប្រាស្រ័យទាក់ទងគ្នាលើបញ្ហានេះរវាងអង្គការ និងអង្គការដែលបញ្ជូនក្មេងប្រុស ធ្វើឱ្យមានកង្វះការយល់/ស្គាល់បញ្ហានេះ ហើយប្រហែលមិនមែនតែខេត្តនេះទេ ខេត្តផ្សេងទៀតក៏មិនសូវយល់ពីបញ្ហានេះដែរ។ គោលដៅរបស់អង្គការខ្លះហាក់ដូចជា រារាំងពួកគេមិនឱ្យចាត់ទុកបញ្ហានេះ ជាបញ្ហាដែលរបស់អង្គការត្រូវយកចិត្តទុកដាក់។

ការយល់ដឹងនៅទីក្រុងមានលក្ខណៈខ្ពស់ តែមិនសូវមានការចែកចាយពតិមាននេះរវាងអ្នកផ្តល់សេវាកម្មជួយក្មេងប្រុសដែលជួបបញ្ហានេះអោយមានប្រសិទ្ធិភាព សូម្បីតែកិច្ចសហការនៅក្នុងអង្គការ រវាងអង្គការនិងអង្គការ។ ប្រសិនបើនិយាយទៅ ការរំលោភបំពានផ្លូវភេទលើក្មេងប្រុស គឺត្រូវគេមើលមិនឃើញ។ មានទ្រឹស្តីរបស់អ្នកស្រាវជ្រាវនិងមានប្រភពធនធានខ្លះៗលើកឡើងពីការធ្វើការជាមួយក្មេងប្រុសដែរ តែគេច្រើនលើកពីបញ្ហាបុរសបរទេសរំលោភបំពានផ្លូវភេទលើក្មេងប្រុស ដោយមិនសូវនិយាយពីការរំលោភបំពានផ្លូវភេទពីសំណាក់អ្នកផ្សេងៗ ដូចជាបុរសខ្មែរ ឬក្មេងដទៃទៀត និងពីមនុស្សស្រីឡើយ។

ការខ្វះចំណេះដឹង និងការអនុវត្តន៏ដើម្បីជួយក្មេងប្រុស ជាហេតុនាំឱ្យមានអង្គការតិចតួច ផ្តល់សេវាកម្មទៅក្មេងប្រុសតាមរយៈការពិគ្រោះបញ្ហា។ តែបុគ្គលិកដែលមានចំណេះដឹង ពីបញ្ហានេះជា រឿយៗមានការផ្តាច់ចេញពីគេ ហើយកម្រទទួលបានវគ្គបណ្តុះបណ្តាលដែលជួយគាំទ្រ និងការគាំទ្រការងារ (supervision) ដើម្បីឱ្យពួកគេអាចអភិវឌ្ឍន៏ជំនាញគាំទ្រនេះអោយកាន់តែមានប្រសិទ្ធភាព ដែលមានលក្ខណៈយូរអង្វែង។ មួយភាគធំនៃបុគ្គលិកបានបញ្ចេញនូវការខកចិត្ត និងភាពគ្មានជំនួយដោយសារតែការខ្វះ "បណ្តាញទំនាក់ទំនង" ដើម្បីអោយពួកគេយល់ពីបញ្ហាក្មេងប្រុស។ ក្មេងប្រុសជារឿយៗត្រូវគេសំលឹងមើលក្នុងន័យ អវិជ្ជមានដូចជា មានបញ្ហាអាកប្បកិរិយា ឬមានភាពលំបាកធ្វើការជាមួយ និងតំរូវការរបស់ពួកគេ ក្នុងនាមជាជនរងគ្រោះ និងអ្នកដែលរួចផុតពីការរំលោភបំពានមិនត្រូវបានគេយល់ និងទទួលស្គាល់ឡើយ។

មានចន្លោះខ្វះខាតសំខាន់ៗមួយកើតឡើងរវាងចំណេះដឹង និងជំនឿដែលជឿ ដោយមនុស្សធំពេញវ័យដែលយើងបានសសម្ភាសន៏ជាមួយ និងការពិតដែលក្មេងប្រុសដែលស្ថិតនៅក្នុងស្ថានភាពនេះបានរៀបរាប់។

## ការគាំទ្របុគ្គលិក និងតម្រូវការវគ្គបណ្តុះបណ្តាល

តម្រូវការនៃការគាំទ្រ និងវគ្គបណ្តុះបណ្តាលរួមមាន ព័ត៌មានជាមូលដ្ឋានពីការរំលោភបំពានផ្លូវភេទលើក្មេងប្រុស រហូតទៅដល់ការអភិវឌ្ឍន៏ជំនាញឯកទេសនានាដើម្បីអាចគាំទ្រក្មេងប្រុសបន្ទាប់ពីការរំលោភបំពាន។ នៅគ្រប់តំបន់ទាំងអស់ មានអ្នកចូលរួមជាច្រើនដែលកំណត់តម្រូវការរបស់ពួកគេថា ពួកគេត្រូវការធ្វើយ៉ាងណាឱ្យកាន់តែមានភាព "ជិតស្និទ្ធ" ជាមួយក្មេងប្រុស ដើម្បីចូលទៅជិតក្មេងប្រុស និងចង់បានឧបករណ៏ និងគំនិតជាក់លាក់ដែលជួយឱ្យពួកគេអាចកសាងចំណងទំនាក់ទំនងជាមួយក្មេងប្រុសបាន។ តម្រូវការចំបាច់ផ្សេងទៀត មានដូចជាការគាំទ្រការងារ (supervision) និងការមានឱកាសជួបអ្នកដទៃទៀត ដែលធ្វើការស្រដៀងនឹងគ្នានេះដែរ។ ពតិមានបន្ថែម សូមមើលនៅក្នុងរបាយការណ៏ចុងក្រោយ។

អ្នកចូលរួមបានកំណត់ឧបសគ្គសំខាន់ៗរបស់អង្គការក្នុងការអភិវឌ្ឍន៍ការយល់ដឹងនិងការជួយដែលពាក់ព័ន្ធនឹងបញ្ហានេះ គឺទាក់ទងទៅនឹងការសហការរវាងអង្គការ និងអង្គការ ជាពិសេសពេលដែលអង្គការកំពុងតែស្វែងរកជំនួយថវិការ។ ករណីខ្លះបានលើកឡើងពីការខ្វះកិច្ចសហការ និងភាពមិនជឿទុកចិត្តគ្នារវាងអ្នកដែលមិនទាក់ទងនឹងសាសនា និងអង្គការដែលកាន់សាសនាណាមួយពិតប្រាកដ។ ខ្លះកត់សំគាល់ថាម្ចាស់ជំនួយក៏ត្រូវសិក្សាពីតម្រូវការរបស់ក្មេងប្រុសដែរ បើមិនដូច្នោះទេ វិធីសាស្ត្ររបស់ពួកគេក្នុងការជួយក្មេងប្រុសមិនមានភាពច្នៃប្រឌិតឡើយ។ ចំនុចសំខាន់មួយទៀតគឺ អំណាចខុសគ្នារវាងអង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយ និងភាពស្ទាក់ស្ទើរក្នុងការប្រឈមមុខនឹងការពិតដែលថានៅក្នុងអង្គការពិតជាមានការរំលោភបំពានផ្លូវភេទលើក្មេងប្រុសកើតឡើងមែន។

## អនុសាសន៍នានា

តាមរយៈការស្រាវជ្រាវ ការវិភាគ និងទិន្និន័យ អនុសាសន៍ដែលផ្អែកលើភស្តុតាងនៃការផ្តល់សេវា កម្ម និងការអភិឌ្ឍន៍នៃការស្រាវជ្រាវនឹងមានរៀបរាប់នៅក្នុងចំនុចខាងក្រោម។ នេះគ្រាន់តែជាការសង្ខេបចំនុច សំខាន់ៗ ហើយសូមមើលចំនុចលំអិតនៅក្នុងរបាយការណ៍ចុងក្រោយ។ វានឹងចំណាយថាមពល ពេលវេលា និងការប្តេជ្ញាចិត្តរយៈពេលយូរអង្វែងដើម្បីឱ្យគំនិតទាំងអស់នេះអាចចាប់ផ្តើមដំណើរការបាន។

## គោលការណ៍ណែនាំនានា

សេវាកម្មដែលមានរួចហើយ និងសេវាកម្មថ្មីនានា គួរតែដំណើរការដោយផ្អែកលើក្មេងប្រុសដែល មានន័យថា ការបញ្ចេញសកម្មភាពនានា គឺគួរធ្វើដោយផ្អែកលើគោលការណ៍ក្នុងការអភិវឌ្ឍន៍ការជួយ និង ការគាំទ្រដែលគោលការណ៍ទាំងនោះមានដូចជា:

- សុវត្ថិភាព
- ការផ្តល់អំណាច និងជម្រើសនានា
- ការយល់ចិត្ត
- ការរក្សាការសម្ងាត់
- ចំណងទំនាក់ទំនងដែលគួរឱ្យទុកចិត្ត
- កិច្ចការពារ
- ការទទួលស្គាល់
- ការគោរព
- ការបញ្ចេញសម្លេង (អ្វីដែលក្មេងប្រុសចង់និយាយចេញ)
- ការទទួលយក

- ការមិនវិនិច្ឆ័យ
- ការស្រឡាញ់ភាពជាសមាជិកនៅក្នុងក្រុម/សហគមន៍ និងក្តីស្រឡាញ់

# ធាតុសំខាន់ៗនៃការជាសះស្បើយ

**ដើម្បីជាសះស្បើយ, ខ្ញុំត្រូវការ...**

- សុវត្ថិភាព
- មានជំរើសនានា
- អ្នកស្តាប់ខ្ញុំ
- ការការពារ
- ការផ្តល់អំណាចអោយខ្ញុំ
- ជឿខ្ញុំ
- ការលើកទឹកចិត្ត
- ទំនាក់ទំនងដែលទុកចិត្ត
- ទទួលស្គាល់/ទទួលយកខ្ញុំ
- ការយល់ចិត្តពីអ្នក
- មិនវិនិច្ឆ័យខ្ញុំ
- ការស្រលាញ់
- ការរក្សាការសំងាត់
- បញ្ចេញសំលេងទាក់ទងនឹងរឿងអ្វីដែលប៉ះពាល់ដល់ខ្ញុំ
- អ្នកដែលទន់ភ្លន់ និង អត់ធ្មត់ ដើម្បីថែទាំខ្ញុំ
- អ្នកគោរពសិទ្ធិរបស់ខ្ញុំ



## គោលការណ៍ណែនាំដ៏ល្អបំផុតក្នុងការអនុវត្តន៍

ដូចគ្នានេះដែរ សេវាកម្មដែលមានស្រាប់ និង សេវាកម្មថ្មីនានា គួរតែបង្កើតឡើងដោយផ្អែកលើមូលដ្ឋាន គ្រឹះ និងការរួមបញ្ចូលគ្នានៃគោលការណ៍ណែនាំក្នុងការអនុវត្តន៍ ដែលនឹងមានរៀបរាប់នៅខាងក្រោម។ របាយការណ៍ពេញលេញនឹងពន្យល់ពីបញ្ហានេះលំអិតបន្ថែមទៀតៈ

- បើអាចទៅរួចគឺក្មេងប្រុសគួរតែបានរស់នៅជាមួយគ្រួសារ និងសហគមន៏
- ចូរមើល ឬវិភាគលើរូបគាត់ (ក្មេងប្រុស) ក្នុងនាមគាត់ជាមនុស្សម្នាក់ទាំងមូល
- គិតផលប្រយោជន៏អតិថិជនជាការសំខាន់ និងផ្តោតលើភាពខ្លាំងរបស់គាត់
- បញ្ចូលវិធីសាស្រ្តដែលទាក់ទងនឹងច្បាប់សំរាប់កុមារ និងសិទ្ធិមនុស្ស
- ការអនុវត្តន៏ការប្រឆាំងនឹងការរើសអើង
- បច្ចេកទេសនានាដើម្បីឱ្យមានភាពស្និទ្ធស្នាលជាមួយក្មេងប្រុស និងបុរស
- ប្រើវិធីសាស្រ្តសហការ និងសម្របសម្រួល
- ការបណ្តុះបណ្តាលបុគ្គលិក ការគ្រប់គ្រង (ការគាំទ្រការងារ ឬ Supervision) ការកសាងសមត្ថភាព ការគាំទ្រ និង ការថៃទាំខ្លួនឯង
- ការអនុវត្តន៏ដែលមានការឆ្លុះបញ្ចាំង ការវាយតម្លៃ និងសកម្មភាពនៃការស្រាវជ្រាវ

## ប្រភេទអន្តរាគមន៏ដែលស្របទៅនឹងតម្រូវការនានា

### *កិច្ចបង្ការ*

ការបង្កើនការយល់ដឹងលើការប្រើប្រាស់នូវអ្វីដែលថ្មីនិងមានស្រាប់ ដើម្បីបង្កើតអោយមានវិធីសាស្រ្ត និង បណ្តាញការងារនានានៅក្នុងចំណោមសហគមន៏ និងវិស័យសាធារណៈ ក្មេងៗនិងក្រុមគ្រួសារ អ្នកផ្តល់ជំនួយ អង្គការ បុគ្គលិក និងរដ្ឋាភិបាល។ ចំណុចសំខាន់នោះគឺ ត្រូវជំនះជំនឿទាំងឡាយអំពីការរំលោភបំពានផ្លូវភេទក្មេងប្រុសដែលមិនមានប្រយោជន៏ និង នាំឱ្យមានគ្រោះថ្នាក់។ ការសិក្សាស្វែងយល់បន្ថែមគួរតែមានដូចតទៅៈ

- ពង្រីកនូវការធ្វើការងារជាមួយក្មេងប្រុសដោយផ្តោតលើ"កិច្ចការពារខ្លួនឯង" ដែលការងារទាំងនោះ រួមមាន"មិត្តអប់រំមិត្ត" កម្មវិធីនៃការគាំទ្រ និងសកម្មភាពសុវត្ថិភាពសង្គមដែលលើកឡើងពីបញ្ហាជាក់លាក់ដែលទាក់ទងនឹងក្មេងប្រុស។
- បង្កើតនូវជម្រើសនានាដែលមានលក្ខណៈពិតប្រាកដ និងវិធីសាស្រ្តនានាដែលអាចជួយឱ្យក្មេងប្រុស គេចចេញពីការរកលុយតាមរយះការនុញ្ញាតិឱ្យគេកេងប្រវ័ញ្ចផ្លូវភេទ។
- មានកន្លែងសុវត្ថិភាព២៤ ម៉ោង សំរាប់ក្មេងប្រុស ដើម្បីពួកគេគេចចេញពីស្ថានភាពនៃការរំលោភបំពាន។

- ការងារជាលក្ខណៈគ្រួសារដែលលើកឡើងពីកិច្ចការពារកុមារ ការលើកទឹកចិត្តពីការចិញ្ចឹមបីបាច់ក្មេងប្រុស ការកត់សំគាល់ និងការកាត់បន្ថយភាពប្រថុយប្រថាននានាដែលទាក់ទងនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ។
- ការងារជាលក្ខណៈគ្រួសារដែលលើកឡើងពីរចនាសម្ព័ន្ធបុព្វហេតុនៃសេដ្ឋកិច្ច និងភាពមិនស្មើគ្នាក្នុងសង្គម និងបញ្ហាដែលទាក់ទងនានា។
- បង្កើតគោលការណ៍ការពារកុមារឱ្យមានប្រសិទ្ធិភាព នៅគ្រប់ស្ថាប័នទាំងអស់ រួមមានបណ្តុះ បណ្តាលបុគ្គលិក ដើម្បីឱ្យពួកគេអាចកត់សំគាល់ និងធ្វើអន្តរាគមន៍ នៅពេលមានភស្តុតាងបង្ហាញពីការរំលោភបំពាន ដែលអាចកើតមានលើក្មេងប្រុសពីសំណាក់មនុស្សធំ ក្មេង១ដទៃ និងក្មេងជំទង់ដទៃទៀត។
- មិត្តអប់រំមិត្តនិងការគាំទ្រដែលទាក់ទងនឹងបញ្ហាសុខភាពផ្លូវភេទ ទំនាក់ទំនងនានា ច្បាប់ និងការទទួលខុសត្រូវ ដោយរួមបញ្ចូលការមានទំនាក់ទំនងផ្លូវភេទបែបវិជ្ជមាន។
- អភិវឌ្ឍន៍ធនធាននានារបស់អង្គការ ដូចជាឧបករណ៍និងសម្ភារៈសំរាប់ធ្វើការជាមួយក្មេងប្រុស ដែលទាក់ទងនឹងការរំលោភភេទអោយមានលក្ខណៈជាសាធារណៈ ហើយត្រូវមានលក្ខណៈពិតប្រាកដ (មិនមែនផ្តោតតែលើការរំលោភភេទពីសំណាក់បរទេសប៉ុណ្ណោះនោះទេ) ព្រមទាំងប្រើប្រាស់ការផ្សព្វផ្សាយតាម វិទ្យុ និងប្រពន្ធ័ផ្សព្វផ្សាយ ដទៃ១ទៀត។
- ការពង្រីកការសហការជាលក្ខណៈជាតិនិងអន្តរជាតិ ដើម្បីកំណត់និងទប់ស្កាត់ជនមុខសញ្ញា (អ្នកប្រ ព្រឹត្ត) ពីការរំលោភបំពានផ្លូវភេទលើកុមារ។
- ងាយស្រួលក្នុងការទទួលព័ត៌មាន និងមានលក្ខណៈអនាមិក មានការគាំទ្រ និងការបញ្ជូនក្មេងប្រុស និងឪពុកម្តាយ ឧទាហរណ៏ៈមានបណ្តាញជួយតាមទូរស័ព្ទ

## ការជាសះស្បើយ និងការគាំទ្រ

ការខិតខំប្រឹងប្រែងគួរតែមានដើម្បីឆ្លើយតបឱ្យបានឆាប់រហ័ស ទៅនឹងការជួយក្មេងប្រុសឱ្យ ជាសះស្បើយពីការរំលោភបំពាននិងការកេងប្រវ័ញ្ច ដូចជាការផ្តល់ព័ត៌មានអំពីជម្រើសនានា ដែលមានលក្ខណៈ អាចបត់បែនបាន។ ជាការសំខាន់ដែលត្រូវដឹងថាសំរាប់ជម្រើសទាំងនោះ ត្រូវទុកពេលឱ្យក្មេងប្រុសបានគិត និងមានឱកាសចាកចេញ ឬត្រឡប់មកទទួលការគាំទ្រនោះវិញបានគ្រប់ពេល។ ដោយសារតែបទពិសោធន៏របស់ ពួកគេ កុមារជាច្រើនមិនទុកចិត្ត និងមិនគោរពមនុស្សពេញវ័យទេ។ ហេតុនេះ ដើម្បីឱ្យពួកគេមានការទុកចិត្ត និងការគោរព យើងត្រូវការពេលវេលាយូរ។ ភាពអត់ធ្មត់ ជម្រើស និងវិធីសាស្ត្រដែលធ្វើឱ្យក្មេងប្រុសមានភាពងាយស្រួលក្នុងការស្វែងរកសេវាកម្មដែលជាចំណុចស្នូល។ ចំណុចទាំងនោះរួមមាន :

- ការស្វែងយល់ដែលប្រកបដោយភាពជាក់លាក់ និងលំអិតពីភាពប្រថុយនឹងគ្រោះថ្នាក់ និងតម្រូវការនានា
- ការគាំទ្រផ្នែកវិជ្ជសាស្ត្រដោយមានលក្ខណៈប្រុងប្រយត្ន័ និងយកចិត្តទុកដាក់

- ការគាំទ្រទាក់ទងនឹងបញ្ហាច្បាប់
- ទីកន្លែងសុវត្ថិភាព ដោយផ្តល់ពេលក្នុងការគិតនិងស្តាប់
- ជម្រើសនៃការពិគ្រោះបញ្ហាដោយចាត់ទុកអតិថិជនជាធំ និងការផ្តោតលើភាពខ្លាំង ដើម្បីឆ្លើយតបទៅនឹងការ តម្រូវការនានាទាំងតំរូវការរយៈពេលខ្លី និងរយះពេលវែងរបស់ក្មេងប្រុស
- ផែនការក្នុងការព្យាបាលដែលមានលក្ខណៈបន់បែន( ឬការពិគ្រោះបញ្ហា)
- មានប្រភេទផ្សេងៗនៃការគាំទ្រជាលក្ខណៈក្រុម និងមិត្តអប់រំមិត្ត
- ជំនាញបំនិនជីវិតសំរាប់ក្មេងប្រុស ដូចជាការហ៊ានឆ្លើយតប (Assertive) ការធ្វើសេចក្តីសម្រេចចចិត្ត ការរៀនរស់នៅជាមួយបញ្ហា។
- ការអប់រំ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការគាំទ្រដើម្បីជួយក្មេងប្រុសអោយអភិវឌ្ឍនូវវិធីសាស្ត្រជាក់លាក់ដែលគេចផុតពីការកេងប្រវ័ញ្ចផ្លូវភេទ។
- កន្លែងងាយស្រួលក្នុងការទទួលសេវា ដែលអាចរក្សាការសម្ងាត់បាន និងមានលក្ខណៈឯកជន។
- អភិវឌ្ឍន៏បុគ្គលិក និងអ្នកអាជីពដែលបានទទួលការបណ្តុះបណ្តាល ឱ្យមានឆន្ទៈ និងប្រកបដោយជំនាញ
- ជួយក្មេងប្រុសដែលមានបញ្ហាជាមួយការប្រើថ្នាំញៀន
- ការជួយព្យាបាលដែលប្រកបដោយឯកទេស និងយកចិត្តទុកដាក់លើបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តដែលមានសភាពធ្ងន់ធ្ងរ។
- ការផ្តល់ព័ត៌មានដែលពិតប្រាកដពីការរំលោភបំពាន ផលប៉ះពាល់ និងការជាសះស្បើយ។
- ការគាំទ្រគ្រួសារដើម្បីជួយឱ្យឪពុកម្តាយយល់ និងអភិវឌ្ឍន៍នូវជំនាញការពារនិងគាំទ្រ លើកកម្ពស់បន្ថែមទៀតនូវការរក្សាការសម្ងាត់ និងជួយគាំទ្រអារម្មណ៏របស់ពួកគេ។
- ការគាំទ្រ និងក្រុមការងារសំរាប់ផ្តល់ពិតមានដល់ឪពុកម្តាយ និងបុគ្គលិកវិជ្ជាជីវៈនានា
- បង្កើតសេវាកម្មជួយតាមទូរស័ព្ទដោយមិនបញ្ចេញឈ្មោះ

## ការស្វែងរកការគាំទ្រមតិដើម្បីអោយការអនុវត្តន៏បានប្រសើរឡើង

ការស្វែងរកមតិគាំទ្រ គឺទាក់ទងខ្លាំងជាមួយនឹងសិទ្ធិមនុស្ស និងការផ្តល់អំណាចដើម្បីឱ្យមនុស្សទទួលបាននូវតម្រូវការដែលខ្លួនចង់បាន។ ដើម្បីបង្កើតឱ្យមានការគាំទ្រប្រកបដោយប្រសិទ្ធិភាពក្នុងការ គាំទ្រយុវវ័យ វ៉ាទាមទារឱ្យមានការចូលរួមពីភ្នាក់ងារនានា និងពីអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ។ ជាការសំខាន់យើងត្រូវដឹងថាមានកុមារជាច្រើនដែលបរាជ័យ ឬត្រូវបានព្រងើយកន្តើយពីសំណាក់អ្នកផ្តល់សេវាកម្មទាំងនោះ។ ដូចនេះជាការចាំបាច់ដែលបុគ្គលិក និងអ្នកអាជីពទាំងអស់គួរប្រាកដថា ពួកគេពិតជាអាចធ្វើការស្វែងរកការគាំទ្រមតិ ដើម្បីជួយក្មេងប្រុសឱ្យបានជួបនឹងតម្រូវការរបស់ពួកគេ។ ចំណុចសំខាន់គឺ ត្រូវផ្តោតលើអន្តរាគមន៏ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ក្មេងប្រុស ដែលរងការរំលោភបំពាន

(វិធីសាស្ត្រយកអតិថិជនជាធំ)។ ការស្វែងរកការគាំទ្រមតិអាចដើរតួនាទីដ៏សំខាន់នៅក្នុងផ្នែកនេះ។ ការបញ្ចូលមតិ ឬការផ្តល់ឱ្យកុមារមានសម្លេង នៅក្នុងការអភិវឌ្ឍន៍សេវាកម្ម វានឹងជួយអោយពួកគេកសាងបាននូវជំនាញ និងសេចក្តីទំនុកចិត្តដែលចាំបាច់ក្នុងការ ញ៉ាំងអោយកុមារអាចធ្វើការ ស្វែងរកការគាំទ្រមតិសំរាប់ខ្លួនឯងបាន ទាន់ពេលវេលានាពេលអនាគត។

ការស្វែងរកការគាំទ្រមតិនឹងអាចកើតឡើងដូចដែលមាននៅខាងក្រោមៈ

- កន្លែងសាធារណៈជន
- ប៉ូលីស និងប្រព័ន្ធយុត្តិធម៌ឧក្រិដ្ឋកម្ម
- ក្រុមវិជ្ជាជីវៈនានា (ឧ. វេជ្ជបណ្ឌិត, គ្រូពេទ្យចិត្តវិកលវិទ្យា)
- អ្នកផ្តល់ជំនួយ
- អង្គការ និងបុគ្គលិក
- សម្ពន្ធ័ភាព វេទិការ និងបណ្តាញការងារ
- បណ្តាញការពារកុមារ
- ស្ថាប័នអប់រំ និងអាជ្ញាធរ
- រដ្ឋាភិបាល
- ស្ថាប័នប្រពន្ធ័ផ្សព្វផ្សាយនានា (ដើម្បីធានានូវភាពឯកជនផ្ទាល់ខ្លួន, ការរក្សាការសម្ងាត់ និងការផ្សព្វផ្សាយចេញនូវបញ្ហាដ៏ពិតប្រាកដនិងមានលក្ខណៈត្រឹមត្រូវ)

ការស្វែងរកការគាំទ្រមតិ អាចរួមមានការអប់រំដល់ក្រុមដែលបានរៀបរាប់ខាងលើ ដើម្បីជួយឱ្យពួកគេយល់ពីបុព្វហេតុនៃការរំលោភបំពានផ្លូវភេទ និងយល់ពីរបៀបដែលពួកគេអាចឆ្លើយតបទៅនឹងក្មេងប្រុស។

## សំណួមពរនានាចំពោះកម្មវិធីនានាដែលមានស្រាប់

អ្វីចំបាច់សម្រាប់សេវាកម្មដែលមានស្រាប់នោះគឺ សេវាកម្មត្រូវតែមានសភាពបត់បែន អាចឆ្លើយតបបាន និងផ្តល់បរិយាកាសសុវត្ថិភាពសំរាប់បុគ្គលិកដែលត្រូវការពេលវេលាក្នុងការកសាង ចំណងទំនាក់ទំនងរឹងមាំជាមួយក្មេងប្រុស។ ដើម្បីអាចកសាងទំនាក់ទំនងដ៏រឹងមាំគឺត្រូវការប្រើវិធីសាស្ត្រដែលចាត់ ទុកអតិថិជនជាធំដោយផ្តោតលើស្ថានភាពនានាដែលមានសារៈសំខាន់សំរាប់ក្មេងប្រុស។ អនុសាសន៍នានាដែលមានខាងក្រោមនេះ មិនបានលំអិតគ្រប់ជ្រុងជ្រោយពេកនោះទេ តែជាតំណាងអោយចំនុចសំខាន់ៗនានាក្នុង ការអភិវឌ្ឍន៍បន្ថែមនូវ ការយល់ដឹង និងការឆ្លើយតបទៅនឹងការមានចំណងទំនាក់ទំនងជិតស្និទ្ធជាមួយក្មេងប្រុស/ បុរស និងសេវាកម្មនានាៈ

**ចំណាយពេលវេលាក្នុងការស្វែងយល់ពី**តិរិយាបទ ចំណេះដឹង និងបទពិសោធន៍ដែលបង្កប់ខាងក្រោមការរំលោភបំពានផ្លូវភេទលើក្មេងប្រុស កំណត់ភាពខ្លាំង ចងសម្ព័ន្ធភាព និងស្វែងយល់ពីតំរូវការដែលទាក់ទងទៅនឹង

សេវាកម្មនាពេលបច្ចុប្បន្ន។ សូមបញ្ចូលបុគ្គលិកឱ្យបានចូលរួមក្នុងដំណើរការនេះ ជាពិសេសអ្នកអាជីព និងអ្នកដទៃដែលបានចំណាយពេលយ៉ាងច្រើនជាមួយក្មេងប្រុស។

**ការសើរើឡើងវិញនូវការអនុវត្តន៏នាពេលបច្ចុប្បន្ន**ដែលទាក់ទងទៅនឹងការរំលោភបំពានផ្លូវភេទលើក្មេងប្រុស ការប្រើប្រាស់គោលការណ៏ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ក្មេងប្រុស និងការអនុវត្តន៏ដ៏ចាំបាច់ ដើម្បីអភិវឌ្ឍ ផែនការសកម្មភាពអោយឆ្លើយតបទៅនឹងចន្លោះខ្វះខាតដែលបានលើកឡើង។

**សិក្សាស្វែងយល់ពីតម្រូវការការបណ្តុះបណ្តាលនិងការគាំទ្រ** ជាមួយបុគ្គលិក និងចែករំលែកពត៌មាន នេះជាមួយអ្នកផ្តល់ជំនួយ និងបុគ្គលពាក់ព័ន្ធផ្សេងទៀត។

**អភិវឌ្ឍន៏រចនាសម្ព័ន្ធនៃការគ្រប់គ្រងករណី**ជាមួយបុគ្គលិកដែលមានឈ្មោះក្នុងការសម្របសម្រួល និងផ្តល់ការ គាំទ្រជាបន្តដល់ក្មេងប្រុស។

អភិវឌ្ឍន៏នូវការប្រើធនធាន និង**ការគាំទ្របន្តឱ្យមានប្រសិទ្ធិភាព និងការគ្រប់គ្រងបុគ្គលិក** ដោយរួមមាន ការកំណត់នូវតម្រូវការខុសៗគ្នារវាងបុរស និងស្ត្រី។

**ពង្រឹកកម្មវិធីបណ្តុះបណ្តាលនានា** ដើម្បីបញ្ចូលបញ្ហាដែលទាក់ទងនឹងក្មេងប្រុស/បុរស អោយកាន់តែជាក់លាក់ ដោយផ្តល់ឱកាសដល់បុគ្គលិក និងការគ្រប់គ្រងក្នុងការអភិវឌ្ឍន៏ជំនាញនៃការឆ្លើយតបទៅនឹងតំរូវការរបស់ក្មេងប្រុស (ផ្សារភ្ជាប់តំរូវការទាំងនោះទៅនឹងការគ្រប់គ្រង និងការគាំទ្រការងារ)។

**ពង្រឹកកម្មវិធីដែលមានស្រាប់** ឬបន្ថែមកម្មវិធី ឬបុគ្គលិកឯកទេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ក្មេងប្រុស និងជម្រុញអោយមានការអភិវឌ្ឍន៏ការងារខាងផ្នែកនេះ។

**ផ្តល់ឱកាសសំរាប់ក្មេងប្រុសក្នុងការបញ្ចេញសម្លេង** និងបានចូលរួមក្នុងការអភិវឌ្ឍន៏សេវាកម្ម។

**ផ្តល់ពេលនិងធ្វើការចាត់តាំងបុគ្គលិកដើម្បីចូលរួមក្នុងវេទិការដែលមានលក្ខណះទូលំទូលាយ**ដើម្បីផ្តល់ព័ត៌ មានពីសេវាកម្មដែលមានលក្ខណៈអភិវឌ្ឍជាបន្តបន្ទាប់សំរាប់ក្រុមនេះ។ ទាំងនេះអាចមានទាំងបណ្តាញការងារដែល មានស្រាប់ ឬការចាប់ផ្តួចផ្តើមបណ្តាញការងារថ្មី។

**ផ្តួចផ្តើមធ្វើការវាយតម្លៃយុទ្ធសាស្ត្រការងារ** ដើម្បីបង្ហាញពីការអភិវឌ្ឍន៍វិធីសាស្ត្រ និងសេវាកម្មថ្មីៗដែលផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាល ការគាំទ្រ និងការគ្រប់គ្រង។

អង្គការបច្ចុប្បន្នដែលកំពុងតែផ្តល់នូវការគាំទ្របែបព្យាបាល ឬការបណ្តុះបណ្តាលដែលទាក់ទងទៅនឹងក្មេងប្រុសត្រូវ**អភិវឌ្ឍន៍សេវាកម្ម**ឱ្យកាន់តែប្រសើរឡើងដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវនេះ។

អង្គការបច្ចុប្បន្នដែលប្រើឧបករណ៍ ឬព័ត៌មានដែលលើកឡើងតែពីការរំលោភបំពានផ្លូវភេទដោយជនបរទេស **ត្រូវកែសម្រួល និង អភិវឌ្ឍធនធាន** ដោយគួរលើកឡើងពីការរំលោភពីសំណាក់ជនជាតិកម្ពុជា ដែលរស់នៅក្នុងសហគមន៍ គ្រួសារ ស្ថាប័ននានាផងដែរ។

**កម្មវិធីថ្មី ឬកម្មវិធីដែលត្រូវអភិវឌ្ឍបន្ថែម**

ទន្ទឹមនឹងពេលដែលក្មេងប្រុសទទួលបាននូវតម្រូវការរបស់ពួកគេតាមរយៈអង្គការដែលមានស្រាប់ សេវាថ្មីៗ និងប្រកបដោយឯកទេសក៏ត្រូវបានគេរកឃើញផងដែរ។ ជាការចំបាច់ក្នុងការផ្តល់នូវជម្រើសដែលមានគុណភាពខ្ពស់ និងជម្រើស ដែលមានការគាំទ្រ និងការថែទាំ ដែលត្រូវវាយតម្លៃដើម្បីស្វែងរកប្រសិទ្ធិភាពដែលល្អបំផុត សំរាប់ក្មេងប្រុស។ ប្រហែលជាសេវាកម្មខ្លះបានប្រើ និងផ្តល់ដល់ក្មេងប្រុសនៅតាមអង្គការរួចទៅហើយ។ ការគ្រប់គ្រងបុគ្គលិក និងអ្នកផ្តល់ជំនួយត្រូវមានការប្តេជ្ញាចិត្តមុតមាំទៅនឹងវិធីសាស្ត្រដែលមានភាពបត់បែន។ ប្រហែលជាអាចយក ទ្រឹស្តី ឬគំនិតថ្មីទាំងនោះទៅសាកល្បងនៅតាមខេត្តនានា។

**មណ្ឌលដែលកុមារអាចសំចតបាន** បុគ្គលិកត្រូវបានបណ្តុះបណ្តាលដើម្បីអាចឆ្លើយតបទៅនឹងតម្រូវការរបស់ក្មេងប្រុសដែលមានបទពិសោធន៍ទទួលរងការរំលោភបំពានផ្លូវភេទ។ មណ្ឌលត្រូវតែជាមណ្ឌលដែលមានលក្ខណៈងាយស្រួលសំរាប់ក្មេងប្រុសក្នុងការទទួលសេវាកម្ម ថែមទាំងមានលក្ខណៈឯកជន និងមានលក្ខណៈរក្សាការសម្ងាត់សំរាប់ពួកគេ។

**កម្មវិធីផ្តល់សេវាកម្មនៅពេលថ្ងៃ** មានផ្តល់សកម្មភាពទាំងឡាយដែលមានដូចជា ការអប់រំ ការបណ្តុះបណ្តាលជំនាញនានា ការបង្កើតកម្មវិធីដែលមានលក្ខណៈទូលាយទាក់ទងទៅនឹងអនាគត កន្លែងដែលកុមារអាចមានសម្ព័ន្ធភាពជាមួយគ្នាដែលមើលពីខាងក្រៅទៅដូចជាស្ងាត់ ការអភិវឌ្ឍន៍ជំនាញសំរាប់ជីវិត និងការរស់នៅក្នុងសង្គមសិល្បៈ និងការសំដែងនានា។ល។

**ក្រុមដែលធ្វើការនៅសហគមន៍** (Assertive outreach) ចុះទៅដល់កន្លែងដែលក្មេងប្រុសរស់នៅ ឬទៅដល់កន្លែងដែលពួកគេមានអារម្មណ៍សុខស្រួល ។

**កន្លែងសុវត្ថិភាពដែលបំរើសេវាកម្ម២៤ម៉ោង** សំរាប់ក្មេងប្រុសដើម្បីឱ្យពួកគេមានពេលសំរាកមួយរយៈ ហើយអាចគិតពិចារណាអំពីជម្រើសនិងដំណោះស្រាយនានា ដោយមានអាហារ និងកន្លែងសំរាប់ស្នាក់នៅ ។

**អភិវឌ្ឍន៍ជម្រើសជាក់ស្តែងនានាទាក់ទងនឹងការរកប្រាក់ចំណូល ជាជាងតាមរយៈការរកស៊ីផ្លូវភេទ**

**ឱកាសសំរាប់មិត្តគាំទ្រមិត្ត** ដោយមានការចូលរួមពីក្មេងប្រុស និង/ឬ បុរសដែលរួចផុតពីការរំលោភបំពានផ្លូវភេទ ដោយរួមមានកម្មវិធីជួយសង្គ្រោះ វេទិការដែលជួយអោយមានការអភិវឌ្ឍន៍នានា និងកិច្ចប្រឹងប្រែងក្នុងការស្វែងរកការគាំទ្រមតិ ។

**សេវាកម្មជួយកុមារដែលមានបញ្ហាក្នុងការប្រើគ្រឿងញៀន** ដោយសហការជាមួយនឹងសេវាកម្មដទៃរួមមាន ការតាមដានឱ្យបានម៉តចត់ពីការគាំទ្រការបន្សាបគ្រឿងញៀន និងកម្មវិធីការពារការការលាប់ឡើងវិញនៃការប្រើគ្រឿងញៀន ។

**ការជួយតាមរយៈទូរសព្ទ័សំរាប់គាំទ្រក្មេងប្រុសគ្រាមានអាសន្ន ដោយមានការផ្តល់ព័ត៌មាន ឱវាទ និងការបញ្ជូន ។** ការធ្វើបែបនេះត្រូវការផ្តួចផ្តើមគំនិតដើម្បីអនុវត្តពីសំណាក់អ្នកផ្តល់សេវាដែលពាក់ពន្ធ័នឹងបញ្ហានេះ ។ កម្មវិធីនេះក៏ត្រូវមានការចូលរួមជួយគាំទ្រដល់គ្រួសារ និងអ្នកដែលគាំទ្រក្មេងប្រុសដែរ ។

**ក្រុមអ្នកឯកទេស** ដើម្បីផ្តល់ការពិគ្រោះបញ្ហា និងគាំទ្រដល់ក្រុមក្មេងប្រុស និងផ្តល់វគ្គបណ្តុះបណ្តាលដល់ក្រុមនេះជាបន្តបន្ទាប់ ការជួបដើម្បីគាំទ្រ (supervision) និងការប្រឹក្សា( consultation) និងមានការវាយតំលៃពីសេវាកម្មដែលបានផ្តល់ទៅអោយក្មេងប្រុស ។

**វេទិការដែលមានការចូលរួមពីសំណាក់ភ្នាក់ងារចម្រុះ** ផ្តោតលើបញ្ហានេះ ដើម្បីអភិវឌ្ឍន៍ការសហការដៃគូរការអនុវត្ត និងការយល់ដឹង និងផ្តល់ឱកាសអោយមានការគាំទ្រការងារជាក្រុម (group supervision) ។

**មជ្ឈមណ្ឌលដែលប្រកបដោយធនធាននិងបណ្ណាល័យ** នៅក្នុងចំណោមបុគ្គលិករបស់អង្គការនីមួយៗ អភិវឌ្ឍការប្រមូលផ្តុំធនធានដែលមានលក្ខណៈជាក់លាក់ ដោយរួមមានធនធានតាមប្រព័ន្ធអ៊ីនធឺណែត( online resources) ជាភាសាខ្មែរ។

**ការស្រាវជ្រាវបន្តពីការស្រាវជ្រាវនេះ** ជម្រើសនានាពីសេវាកម្មត្រូវអភិវឌ្ឍន៍សំរាប់ក្មេងប្រុសដែលមានអាយុច្រើន និងបុរសដែលរស់នៅក្នុងសហគមន៍ ដែលពួកគេមិនអាចមានលទ្ធភាពទទួលសេវាកម្មនានា។

**អន្តរាគមន៍អោយបានមុន** ជាមួយកុមារ យុវវ័យ និងមនុស្សវ័យកណ្តាលដែលមានបញ្ហាអាកប្បកិរិយាផ្លូវភេទ ដែលអាចប៉ះពាល់ដល់អ្នកដទៃ ឬជាអ្នកប្រព្រឹត្តអំពើរំលោភបំពានផ្លូវភេទ។

**កម្មវិធីស្រាវជ្រាវដែលមានលក្ខណៈជាបន្តបន្ទាប់** ដែលបានរកឃើញ ហើយមានរៀបរាប់នៅក្នុងផ្នែកដែលមានចំណងជើងថា" អនុសាសន៍នានាសំរាប់ការស្រាវជ្រាវជាក់លាក់"។

## បរិយាកាសនៅជម្រកសុវត្ថិភាព

ជាធម្មតាការឆ្លើយតបទៅនឹងបញ្ហាសង្គមនៅក្នុងប្រទេសកម្ពុជា គឺការដាក់នរណាម្នាក់ទៅក្នុង"មណ្ឌល"។ តែកន្លែងដែលកុមារចូលចិត្ត ហើយអាចធ្វើទៅបាននោះគឺការរស់នៅក្នុងសហគមន៍។ ការសម្រេចចិត្តទាំងអស់ទាក់ទងនឹងកន្លែងសំរាប់កុមារស្នាក់នៅគួរតែផ្អែកលើកត្តាជាច្រើនៈ ការស្វែងយល់ពីតំរូវការរបស់កុមារ ការថ្លឹងថ្លែងពីភាពប្រថុយប្រថាននិងការការពារកុមារពីការរំលោភបំពានផ្លូវភេទ ជម្រើសតំរូវការដែលចេញពីការនិយាយ និងការកត់សម្គាល់លើកុមារ ការអនុវត្តន៍ដោយប្រើគោលការណ៍សមស្របទៅនឹងស្ថានភាពរបស់កុមារ។ ការស្នាក់នៅរបស់កុមារដែលមាន លក្ខណៈយូរអង្វែងនៅក្នុងមណ្ឌល នឹងប៉ះពាល់ដល់លទ្ធភាពរបស់កុមារក្នុងការធ្វើសមាហរណកម្មទៅក្នុងសង្គមវិញ។ ដូចនេះ អនុសាសន៍សំរាប់ការស្នាក់នៅរបស់កុមារត្រូវពិចារណាលើគ្រប់ ចំនុចទាំងអស់ (អាចផ្អែកលើការចង់បានរបស់កុមារដែរ)។

## រស់នៅជាមួយគ្រួសារ ឬសាច់ញាតិ

មានសំណូមពរមួយ បើអាចទៅរួច សូមដាក់កុមារទៅក្នុងគ្រួសារ ឬទុកពួកគេឱ្យនៅជាមួយគ្រួសារកំណើតរបស់ពួកគេ ដោយមានការគាំទ្រទាំងកុមារ(ក្មេងប្រុស) និងគ្រួសារ។ ភាពលំអិតនៃការពិពណ៌នាពីការគាំទ្រអាចមើលនៅក្នុងរបាយការណ៍ពេញលេញ។

## ការថែទាំដោយអ្នកឯកទេស និងនៅតាមសហគមន៍

នៅពេលដែលកុមារមិនអាចទៅរស់នៅជាមួយគ្រួសារកំណើតបាន (ទោះក្នុងរយៈពេលខ្លីឬយូរ ក៏ដោយ) កម្មវិធីឯកទេសក្នុងការថែទាំដោយផ្អែកលើសហគមន៍ (មិនគួរដាក់កុមារអោយលើសពី២ទៅ៤ កន្លែងនោះទេ) គួរតែផ្តល់ដល់កុមារ។ អាស្រ័យលើកាលៈទេសៈ ការថែទាំបែបនេះប្រហែលជាត្រូវផ្តល់តែក្នុងរយៈពេលខ្លី (ហើយត្រូវឱ្យកុមារត្រឡប់ទៅគ្រួសារដើមរបស់គេវិញ) និងត្រូវមានការជួយថែទាំក្នុងគ្រាអាសន្ន ឬជំរើសនានា សំរាប់រយៈពេលយូរអង្វែង។ គួរតែទំនាក់ទំនងឬសំរបសំរួលឱ្យកុមារបានជួបគ្រួសារដើមរបស់ពួកគេ អោយបាន ទៀងទាត់ លើកលែងតែមានការព្រួយបារម្ភពីសុវត្ថិភាពរបស់កុមារ។ ភាពលំអិតនៃជម្រើសទាំងនេះ អាចមើលនៅក្នុងរបាយការណ៍ពេញលេញ។

## គម្រោងផ្តល់កន្លែងស្នាក់នៅដល់ក្មេងប្រុសដែលមានអាយុច្រើន និងមនុស្សប្រុសក្មេង

ករណីខ្លះក្មេងប្រុសដែលមានអាយុច្រើន និងមនុស្សប្រុសវ័យក្មេងគួរតែផ្តល់ការគាំទ្របន្ថែមដោយមិនគួរគិតពីកម្រិតនៃអាយុក្នុងការទទួលសេវានោះទេ។ ពួកគេអាចជួបនូវតម្រូវការបានដោយការរស់នៅជុំគ្នាក្នុងផ្ទះដែលមានលក្ខណៈតូចនៅក្នុងសហគមន៍ ដោយផ្តល់ការគាំទ្រសំរាប់ការស្នាក់នៅ ឬការចេញថ្លៃឈ្នួលសំរាប់ការស្នាក់នៅ ការផ្តល់ជំនាញក្នុងការរស់នៅដោយឯករាជ្យ ។ល។ ការធ្វើបែបនេះបានដោយសារការសហការគាំទ្រពីសំណាក់សេវាកម្មនៅក្នុងសហគមន៍ និងក្រុមធ្វើការនៅសហគមន៍( outreach) ដូចដែលបានរៀបរាប់ខាងលើ។

## កន្លែងស្នាក់នៅដែលមានលក្ខណៈតូច ឬ អ្នកថែទាំ

ការរស់នៅក្នុងមណ្ឌល ឬ ស្ថាប័ននានាគួរតែជៀសវាង លើកលែងតែករណីអាសន្ន ឬត្រូវការខ្លាំងណាស់ នៅពេលដែលជម្រើសដទៃទៀតមិនអាចទៅរួចសោះ។ ករណីអាសន្នទាំងនោះរួមមាន បញ្ហាផ្លូវចិត្ត ឬ សុខភាពផ្លូវកាយធ្ងន់ធ្ងរដោយសារការរំលោភបំពានឬការកេងប្រវ័ញ្ចផ្លូវភេទ។ ក្នុងករណីនេះ កន្លែងដែលមានសុវត្ថិភាពគួរតែត្រូវផ្តល់ដោយមានលក្ខខ័ណ្ឌច្បាស់លាស់ និងអាចត្រឡប់ទៅជម្រើសដែលបានរៀបរាប់ខាងលើវិញបាន។ គួរតែពង្រឹងការរក្សាការសម្ងាត់ និងភាពឯកជន។ របាយការណ៍ពេញលេញនឹងរៀប រាប់ពីភាពលំអិតដែលទាក់ទងនឹងការគាំទ្រដ៏ជាក់លាក់នេះ។

## អនុសាសន៍បន្ថែមនានា

## ការបណ្តុះបណ្តាល ការបង្កើនការយល់ដឹង និងការគាំទ្រសំរាប់បុគ្គលិក

ការបណ្តុះបណ្តាលដែលផ្តោតលើភស្តុតាងត្រូវតែប្រព្រឹត្តឡើង និងចែករំលែកជាមួយបុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលមានទំនួលខុសត្រូវ និងបទពិសោធន៍ ដូចជាអគ្គនាយក ប្រធាន ប្រធានក្រុម និងបុគ្គលិក ដែលផ្តល់ការបណ្តុះបណ្តាល ការជួបដើម្បីគាំទ្រ និងការគាំទ្របែបព្យាបាល។ វប្បធម៌នៃការបង្កើនការយល់ដឹងដែលបានលើក

ពីបញ្ហា ទូទៅនៃការគ្រប់គ្រង ក៏ដូចជាការឆ្លើយតបទៅនឹងអន្តរាគមន៍នានា ត្រូវជម្រុញឱ្យមានគ្រប់លំដាប់ថ្នាក់ ប្រសិនបើចង់បានការផ្លាស់ប្តូរជាប្រយោជន៍ដែលមានរយៈពេលយូរអង្វែង។ អំឡុងពេលដែលការបង្កើនការ យល់ដឹងគឺជាជំហានដំបូង បុគ្គលិកទាំងអស់ត្រូវតែបន្តទទួលបាននូវការគាំទ្រ ដើម្បីជួយពួកគេឱ្យអាចអភិវឌ្ឍន៍ របៀបធ្វើការជាមួយក្មេងប្រុស គ្រួសារ និងអ្នកគាំទ្ររបស់ក្មេងប្រុសអោយកាន់តែមានប្រសិទ្ធិភាព និងមានន័យ។ ទន្ទឹមនឹងនេះផងដែរ បុគ្គលិកដែលជារៀមច្បង ឬពោរពេញដោយបទពិសោធន៍ ក៏ត្រូវការការបណ្តុះបណ្តាលបន្ថែមដើម្បីអភិវឌ្ឍន៍សមត្ថភាពបន្ថែមទៀតក្នុងការធ្វើការជាមួយក្មេងប្រុសផងដែរ។ ការបណ្តុះបណ្តាល ការគាំទ្រ និងការត្រួតពិនិត្យគួរតែធ្វើឡើងដោយបរិយាកាសសុវត្ថិភាព សំរាប់បុគ្គលិក និងក្មេងប្រុស។

- **កែសំរួលវគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះនៃការងារសង្គមកិច្ចដែលមានស្រាប់ ដើម្បីបញ្ចូលចំនុចសំខាន់នានាដែលទទួលបានពីការស្រាវជ្រាវនេះ**

- **អភិវឌ្ឍវគ្គបណ្តុះបណ្តាលដែលមានលក្ខណៈឯកទេស និងការបណ្តុះបណ្តាលក្នុងការធ្វើការជាមួយក្មេងប្រុសដែលត្រូវគេរំលោភបំពានផ្លូវភេទ។ វគ្គទាំងនោះរួមមានៈ និយមន័យ និងការកំនត់ន័យការរំលោភ ការឆ្លើយតបឱ្យសមស្របនឹងតម្រូវការ និងយកចិត្តទុកដាក់ទៅនឹងបញ្ហាដែលក្មេងប្រុសបានរៀបរាប់ ភាពជាមនុស្សប្រុស និង ឥទ្ធិពលនៃវប្បធម៌, ការរំលោភភេទភាពអាម៉ាស់ និងកិត្តិយស, ការងារទាក់ទងនឹងកិច្ច ការពារកុមារ, ផលប៉ះពាល់និងលទ្ធផល, ជំនាញពិគ្រោះបញ្ហា ឧបករណ៍ និងគម្រោងការក្នុងការគាំទ្របុរសដែលរួចផុតពីការរំលោភបំពានផ្លូវភេទ ការដោះស្រាយជាមួយ ជំនឿមិនសមហេតុផលនិងការបដិសេធ ការធ្វើការជាមួយគ្រួសារក្មេងដែលទទួលរងការរំលោភបំពានផ្លូវភេទ វិធីសាស្រ្តក្នុងការគាំទ្រ និងការថែទាំខ្លួនឯងសំរាប់បុគ្គលិក និងការវាយតម្លៃការ អនុវត្តន៍។**

- **អភិវឌ្ឍន៍វគ្គបណ្តុះបណ្តាលសំរាប់ក្រុមនីមួយៗ និងអង្គការក្រៅរដ្ឋាភិបាល ដោយមានការតាមដានការស្វែងយល់ពីតំរូវការនៃវគ្គបណ្តុះបណ្តាល។ វគ្គបណ្តុះបណ្តាលទាំងនោះរួមមានចំណុចសំខាន់ៗមួយចំនួនដូចជា"គោលនយោបាយនិងការអភិវឌ្ឍន៍ការអនុវត្តន៍" ការរួមបញ្ចូលគម្រោងការអនុវត្តសកម្មភាពរបស់អង្គការ និងការវាយតម្លៃ ដែលអាចតាមដានដោយគ្រូបណ្តុះបណ្តាលអោយបានទៀងទាត់។**

- **អភិវឌ្ឍឧបករណ៍ដែលជួយបង្កើនការយល់ដឹងជាមូលដ្ឋាន សំរាប់អនុវត្តនៅតាមអង្គការ និងសហគមន៍ ។ សិក្ខាកាមរបស់ សសក ដែលបានរៀនជំនាញមូលដ្ឋានពីមុនៗ គួរតែអោយចូលរួមជាមួយបុគ្គលិក សសក ពេលមានការរៀបចំការបង្រៀន ការធ្វើដូចនេះជួយអោយសិក្ខាកាម**

**អាចរៀនពីរបៀបប្រើឧបករណ៍ទាំងនោះ។ ឧបករណ៍ ទាំងនោះគួរតែត្រូវបានបង្កើតឡើងតែឯង ហើយថែមទាំងជួយរៀបចំបុគ្គលិកអោយ ចេះប្រើវាថែមទៀតផង។**

- **អភិវឌ្ឍសកម្មភាព ឬបែបផែនជាក់លាក់នៃការគាំទ្រការងារ (supervision) និងការគាំទ្រដល់បុគ្គលិកដែលធ្វើការទាក់ទងនឹងប្រធានបទនៃការរំលោភបំពានផ្លូវភេទ។**
- **ក្នុងការសហការជាមួយអ្នកដទៃ សូមបង្កើតឱ្យមានឱកាសធ្វើជំនួបត្រួតពិនិត្យដែលមានលក្ខណៈជាក្រុម និងកម្មវិធីគាំទ្រសំរាប់បុគ្គលិកដែលធ្វើការនៅក្នុងផ្នែកនេះ។**
- **ក្នុងការសហការជាមួយអ្នកដទៃ សូមបង្កើនធនធាននានាដែលមានលក្ខណៈឯកទេស និងសម្ភារៈនៃការស្រាវជ្រាវនៅក្នុងបណ្ណាល័យដែលអាចងាយយកទៅប្រើបាន។**
- **ក្នុងការសហការជាមួយអ្នកដទៃ បង្កើតវែបសាយជាភាសាខ្មែរទាក់ទងនឹងប្រធានបទបុរសដែលរួចផុតពីការរំលោភបំពានផ្លូវភេទ ដើម្បីជួយគាំទ្របុគ្គលិក និងអង្គការនានា ដែលកំពុងស្ថិតនៅក្នុងការអភិវឌ្ឍន៍។**
- **បង្កើតវេទិការសហការ ដើម្បីញុំាងអោយមានការអភិវឌ្ឍន៍ការងារនៅក្នុងចំណោមបុគ្គលិក លើការធ្វើការជាមួយបុរស និងអភិវឌ្ឍការយល់ដឹងនៅតាម សហគមន៍ក្នុងស្រុក។**
- **ក្នុងការសហការជាមួយអ្នកដទៃ ត្រូវចែករំលែកវគ្គបណ្តុះបណ្តាលដែលបង្កើនការយល់ដឹង ទាក់ទងនឹងប្រធានបទការពារកុមារ និងគោលការណ៍អភិវឌ្ឍន៍អោយបានទូលំទូលាយ ដើម្បីជួយឱ្យបុគ្គលិកមានការឆ្លើយតបប្រកបដោយភាពសមស្រប ប្រសិទ្ធិភាព និងទំនុកចិត្ត។**
- **បង្កើនការយល់ដឹង និងផ្តល់វគ្គបណ្តុះបណ្តាលទាក់ទងនឹងការធ្វើការជាមួយបុរសពេញវ័យ រួមមានបុរសរួមភេទដូចគ្នាដែលពួកគេក៏ជាអ្នករួចផុតពីការរំលោភបំពានផ្លូវភេទផងដែរ។**

### អនុសាសន៍សំរាប់ការស្រាវជ្រាវនាពេលអនាគត

មានតម្រូវការដ៏ជាក់លាក់សំរាប់ធ្វើការសិក្សាស្រាវជ្រាវបន្ថែមដែលទាក់ទងនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើបុរស។ ការសិក្សាស្រាវជ្រាវនេះបានឆ្លើយតបទៅនឹងសំនួរខ្លះៗ ហើយបានកំណត់ឃើញនូវតម្រូវការសិក្សាបន្ថែមទៀតជាច្រើននៅក្នុងប្រទេសកម្ពុជា តម្រូវការសិក្សាបន្ថែមត្រូវបានកំណត់ដូចដែលនឹងរៀបរាប់នៅខាងក្រោម។ ការសិក្សាទាំងនោះគួរតែមានៈ

- **កត្តាប្រថុយប្រថាននានា ឥទ្ធិពល ធម្មជាតិ ប្រេវ៉ាឡង់ និងឌីណាមិកនៃការរំលោភភេទលើក្មេងប្រុសនៅតំបន់ផ្សេងៗ ដូចជាប៉ោយប៉ែត សៀមរាប និងខេត្តដាច់ស្រយាលនានា។ ហើយគួរតែរួម**

បញ្ចូលការរំលោភបំពានផ្លូវភេទ ដែលកើតមានលើអ្នកមានជីវភាពមធ្យម និងបរិយាកាសនៃសហគមន៍ផ្សេងៗទៀត ។

- ការសិក្សាស្រាវជ្រាវទៅអនាគតដែលទាក់ទងទៅនឹងផលវិបាក និងផលប៉ះពាល់ដែលរួមមានទំនាក់ទំនងផ្លូវភេទ ការយល់ច្រឡំនៃយេនឌ័រ ការជាសះស្បើយ ការអភិវឌ្ឍន៍វិធីសាស្ត្រក្នុងការសម្របខ្លួនបែបវិជ្ជមាន និងភាពងាយជាសះស្បើយ (Resilience) របស់ក្មេងប្រុសដែលទទួលរងបទពិសោធន៍នៃការរំលោភបំពានផ្លូវភេទ ។ បើនិយាយអោយសាមញ្ញទៅគឺៈ តើអ្វីខ្លះទៅដែលជួយឱ្យពួកគេជាសះស្បើយ?
- ការឆ្លើយតបរបស់គ្រួសារទៅនឹងការរំលោភបំពានផ្លូវភេទលើក្មេងប្រុស ដើម្បីស្វែងយល់ និងលើកស្ទួយអាកប្បកិរិយា ក្នុងការការពារ និងការទប់ស្កាត់ និងជួយគាំទ្របន្ទាប់ពីការរំលោភបំពានផ្លូវភេទ ។
- ការផ្សារភ្ជាប់រវាងការរងគ្រោះនិងអាកប្បកិរិយារំលោភរបស់កុមារ និងយុវវ័យ និងកត្តានានាដែលជួយឱ្យមានការកាត់បន្ថយការរំលោភបំពានផ្លូវភេទបន្តទៀត ។
- ឥទ្ធិពល និងឌីណាមិកនៃអាកប្បកិរិយារំលោភបំពានរបស់ជនមុខសញ្ញា ការរំលោភភេទ និងការរំលោភសេពសន្ថវៈកុមារពីសំណាក់កុមារដែលមានអាយុច្រើនជាង ឬយុវវ័យ ការយល់ពីឥទ្ធិពលនេះនាំឱ្យមានការអភិវឌ្ឍន៍យុទ្ធសាស្ត្រសំរាប់ការការពារកុមារ ការទប់ស្កាត់ និងការព្យាបាលអ្នករំលោភបំពាន/ជនមុខសញ្ញា ។
- ឥទ្ធិពល និងឌីណាមិកដែលមាននៅក្នុងការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទដោយមនុស្សពេញ វ័យ (ទាំងជនជាតិខ្មែរ និងបរទេស) ដោយរួមមានស្ត្រីផងដែរ ។
- ការរំលោភបំពានផ្លូវភេទលើកុមារដែលមានបញ្ហាពិការភាព ការការពារពួកគេ និងការទប់ស្កាត់ការរំលោភបំពាន ។
- ការរំលោភនិងការកេងប្រវ័ញ្ចផ្លូវភេទលើក្មេងប្រុសនិងបុរសវ័យក្មេងដែលជាជនជាតិវៀតណាម និងអ្នកសហគមន៍ជនជាតិភាគតិចនានា ។
- ជនរងគ្រោះនៃការរំលោភនិងកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងពន្ធនាគារ ។
- បទពិសោធន៍ តម្រូវការ និងការរាវរកសេវាកម្មសំរាប់បុរសបន្ទាប់ពីទទួលរងការរំលោភបំពានផ្លូវភេទកាលពីកុមារភាព ឬពេលពេញវ័យ ។
- បទពិសោធន៍ តម្រូវការ និងការរាវរកសេវាកម្មសំរាប់ក្មេងប្រុស និងបុរសពេញវ័យដែលទទួលរងការរំលោភបំពានផ្លូវភេទ និងការរំលោភបំពានផ្លូវភេទដែលកើតឡើងលើបុរសដែលរួមភេទដូចគ្នានៅក្នុងសហគមន៍ ។
- អាកប្បកិរិយានៃការយល់ព្រមរួមភេទនៅក្នុងចំណោមយុវវ័យនៅប្រទេសកម្ពុជា និងទំនាក់ទំនងទៅនឹងការអភិវឌ្ឍន៍សេវាកម្មសុខភាព និងសេវាកម្មដទៃៗទៀត ។

- **ការសិក្សាស្រាវជ្រាវពីផលប្រយោជន៍ដែលមានលក្ខណៈយូរអង្វែង ដោយទុកពេលមួយរយៈដើម្បីប្រៀបធៀបរវាងសេវាកម្មនានា និងសេវាកម្មដែលទើបមានការផ្តួចផ្តើមនានា ឧទាហរណ៍ដូចជាការថែទាំតាមស្ថាប័ននានា គ្រួសារ និងការថែទាំតាមផ្ទះ។**

## អនុសាសន៍នានាបន្ថែម

ដើម្បីអភិវឌ្ឍកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ អង្គការក្រៅរដ្ឋាភិបាលទាំងអស់ត្រូវបង្កើតសម្ភារៈ ល្បែង និងធនធាននានា សំរាប់ការធ្វើការជាមួយកុមារ ឪពុកម្តាយ និងបុគ្គលិក ដែលឧបករណ៍ទាំងនោះ គួរតែឆ្លុះបញ្ចាំងពីតថភាពពិតនៃអ្នករំលោភបំពាន និងអ្នកប្រព្រឹត្ត ដែលមិនមែនឆ្លុះបញ្ចាំងតែជនរទេស ជាអ្នករំលោភបំពានផ្លូវភេទប៉ុណ្ណោះនោះទេ គឺត្រូវឆ្លុះបញ្ចាំងថា អ្នករំលោភបំពានផ្លូវភេទមានទាំង ជនជាតិខ្មែរ និងកុមារដទៃ និងយុវវ័យនៅគ្រប់មជ្ឈដ្ឋានទាំងអស់ផងដែរ។

វិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធនិងឆ្នៃប្រឌិតត្រូវតែអភិវឌ្ឍ ដោយប្រើបណ្តាញការងារដែលមានស្រាប់ និងវិធីសាស្ត្រនានាដែលមានប្រសិទ្ធិភាព និងសម្ព័នភាពជាមួយថ្នាក់ដឹកនាំរបស់រាជរដ្ឋាភិបាល អង្គការក្រៅ រដ្ឋាភិបាល សហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយក្នុងការបង្កើនការយល់ដឹងពីបញ្ហាសំខាន់ៗដែល ទាក់ទងទៅនឹង ការរំលោភ និងការកេងប្រវ័ញ្ចផ្លូវភេទលើក្មេងប្រុសនៅប្រទេសកម្ពុជា។

យើងក៏ត្រូវរាវរកពីលទ្ធភាពនានានៃការអភិវឌ្ឍន៍ផែនការសកម្មភាព ដើម្បីឈានទៅរកការ អភិវឌ្ឍន៍វិធីសាស្ត្រដែលមាននិរន្តភាពនៅក្នុងចំណោមអង្គការនិងស្ថានប័នរដ្ឋាភិបាលនានា។ សម្ព័នភាព និងអង្គការនានាត្រូវពិចារណាលើវិធី ដែលពួកគេអាចលើកទឹកចិត្តសមាជិកអោយលើកពីបញ្ហានេះនៅក្នុង ស្ថាប័នរបស់ពួកគេ លើកទឹកចិត្តអោយមានការពិភាក្សា ការតស៊ូមតិ និងកំណត់អ្វីដែលទាក់ទងនឹងគោលបំណង។

## មតិយោបល់ចុងក្រោយ

ការស្រាវជ្រាវនេះមានការព្រួយបារម្ភទាក់ទងនឹងការផ្លាស់ប្តូរ ហើយសង្ឃឹមថាការស្រាវជ្រាវនេះនឹងបង្កើនការយល់ដឹង ការប្តេជ្ញាចិត្ត និងទំនុកចិត្ត ក្នុងការជួយគាំទ្រដល់ក្មេងប្រុស ដែលនេះគឺជាផ្នែកមួយនៃការជួយឱ្យមានការផ្លាស់ប្តូរទៅបាន។ ពាក្យពេជន៏ដែលពោលដោយអ្នកស្រាវជ្រាវម្នាក់ឈ្មោះគង់ សុខេម ដែលមានលើកឡើងនៅក្នុងពេលនេះ គឺជាការលើកទឹកចិត្តដល់យើងទាំងអស់គ្នា ដែលមានការយកចិត្តទុកដាក់ចំពោះអ្នកដទៃ។

**ក្នុងពេលស្រាវជ្រាវ មានអ្វីជាច្រើនដែលកើតឡើងនៅក្នុងខួរក្បាល និងបេះដូងរបស់ខ្ញុំ.... ជួនកាលខ្ញុំមានអារម្មណ៍ភ័យរន្ធត់ និងសោកស្តាយ ឈឺចាប់ និងច្របូកច្របល់ ពេលដែលខ្ញុំស្តាប់សាច់រឿងរបស់ក្មេងប្រុស។ វាមិនមែនជាការងាយស្រួលក្នុងការឱ្យពួកគេបញ្ចេញនូវអ្វីដែលមាននៅក្នុងចិត្តរបស់ពួកគេនោះទេ។ មនុស្សជាច្រើនគិតថា ក្មេងប្រុសមិនអាចខ្មាស់ ឬភ័យខ្លាចក្នុងការនិយាយដូចជាក្មេងស្រីនោះទេ**

**តែតាមពិត មិនដូច្នោះទេ។ ការស្រាវជ្រាវនេះជួយឱ្យខ្ញុំយល់បានច្រើនណាស់....មានហេតុផលជាច្រើនដែលបណ្តាលឱ្យមានបញ្ហានេះកើតឡើង ហើយវាមិនមែនជាជម្រើសរបស់ពួកគេនោះទេ និងក៏មិនមែនដោយសារតែពួកគេភ្លើតភ្លើនដែរ.....**

**ខ្ញុំឃើញពួកគេព្យាយាមលាក់បាំងអារម្មណ៍ និងព្យាយាម "តាំងខ្លួនធ្វើជាជាបុរស" ដែលជាការរំពឹងទុករបស់គ្រួសារ និងសង្គម។ ពួកគេត្រូវការការគាំទ្រ និងការយកចិត្តទុកដាក់ពីមនុស្សដែលនៅជុំវិញពួកគេ.....ពួកគេចង់និយាយ និងត្រូវការនិយាយ យំ និងបង្ហាញការឈឺចាប់ និងភាពសោកសៅរបស់ពួកគេ។ តើពួកគេអាចធ្វើដូច្នោះបានដែរឬទេ? តើសង្គមអាចទទួលស្គាល់ទេ? តើអ្នកដែលជាម្តាយបងប្អូនប្រុសនិងស្រី និងអ្នកថែទាំអាចបង្ហាញការគោរពចំពោះពួកគេបានដែរឬទេ? តើអ្នកអាចផ្តល់តម្លៃ ស្តាប់ និងជឿនូវអ្វីដែលក្មេងប្រុសនិយាយដែរឬទេ?**

អំឡុងពេលនៃការសិក្សាស្រាវជ្រាវ គោលបំណងដែលសំខាន់បំផុតនោះគឺការផ្តល់ឱកាសឱ្យក្មេងប្រុស និងបុរសបញ្ចេញសម្លេងរបស់ខ្លួន។ របាយការណ៍ចុងក្រោយមានពាក្យសម្តីរបស់ពួកគេចំនួន៤០ឃ្លា។ សម្តីទាំងនោះមានអនុភាពណាស់ ថែមទាំងប្រកបទៅដោយថាមពល ដែលសំណូមពរឱ្យយើងស្តាប់ ឱ្យតំលៃ និងផ្តល់កិត្តិយសប្រសិនបើបញ្ហាត្រូវបានរកឃើញ ហើយតម្រូវការរបស់ពួកគេត្រូវបានជួប។ ដើម្បីជួយយើងឱ្យមាន ការប្តេជ្ញាចិត្តចំពោះអ្វី ដែលពួកគេនិយាយ និងជាចុងបញ្ចប់នៃឯកសារនេះ យើងនឹងលើកពាក្យសំដីរបស់បុរសវ័យក្មេងម្នាក់ដែលបានផ្តល់ជាចំណងជើងនៃការស្រាវជ្រាវនេះ។

ពាក្យសម្តីនេះយើងបានសម្រួល ហើយចំពោះសម្តីពេញលេញ លោកអ្នកអាចអានបាននៅក្នុងរបាយការណ៍ចុងក្រោយ។ ពាក្យសម្តីដែលសម្តែងចេញនូវការពិតបានជួយឱ្យយើងយល់ និងប្រាប់យើងពីអ្វីដែលយើង ត្រូវធ្វើប្រសិនបើយើងចង់ជួយក្មេងប្រុស។

**វាជារឿងដែលពិបាករៀបរាប់...មិនគួរជឿ។ ក្មេងប្រុសក៏ដូចក្មេងស្រីដែលបាត់បង់ខ្លួនប្រាណដែរ។ ឪពុកម្តាយខ្ញុំ មិនដឹងពីអ្វីដែលបានកើតឡើងចំពោះខ្ញុំទេ...ហើយមានមនុស្សជាច្រើនដែលដូចខ្ញុំអញ្ចឹង តែគ្មាននរណាយកចិត្តទុកដាក់ឡើយ...**

**កន្លងមកយើងមិនដែលឮពីការរំលោភបំពានផ្លូវភេទលើក្មេងប្រុសនៅក្នុងសង្គមឡើយ ដោយសារតែការខ្វះការយល់ដឹងពីបញ្ហានេះ ទើបបានជារឿងនេះជាបញ្ហាដែលនឹកស្មានមិនដល់។**

**ខ្ញុំនៅតែចងចាំពីអ្វីដែលបានកើតឡើងលើជីវិតខ្ញុំ...ខ្ញុំមិនដែលគិតថាវាអាចកើតឡើងលើក្មេងប្រុសទេ...ខ្ញុំខឹងខ្លាំងណាស់... ខ្ញុំធ្លាប់ព្យាយាមប្រាប់គេដែរ តែពួកគេមិនជឿខ្ញុំទេ។ ដោយសារតែខ្ញុំមិនដឹងពីវិធីអូសទាញ របស់គេ**

ដោយសារតែគ្រួសារខ្ញុំមិនមានអ្វីហូប ...ប្រសិនបើខ្ញុំមិនធ្វើដូច្នោះទេ គ្រួសាររបស់ខ្ញុំនឹងស្លាប់ដោយសារអត់អីហូប និងឈឺចាប់ជាមិនខាន។

បុគ្គលិកមិនដែលដឹងពីរឿងនេះ ខ្ញុំលាក់មិនឱ្យគេដឹង ហើយប្ដូរប្រធានបទទៅ និយាយពីអ្វីផ្សេងវិញ អញ្ចឹងហើយគ្មាននរណាដឹងឡើយ។

ក្មេងប្រុសពិតជាមានអារម្មណ៍អាម៉ាស់ និងខូចកិត្តិយស ពេលអ្នកដទៃដឹងពីការរំលោភបំពាននេះ។ ពួកគេអាម៉ាស់ខ្លាំងពេលត្រូវគេដឹង។ ក្មេងស្រីមានភាពអាម៉ាស់ ហើយមិនអាចលាក់បាន ... ប្រសិនបើមានគេចាប់ផ្ដើមនិយាយពីបញ្ហានេះ គេអាចប្ដឹងបាន តែក្មេងប្រុសមិនអាចធ្វើដូចនេះបាននោះទេ... ពួកគេជេរស្ដីអោយយើង។ ក្មេងប្រុស...ពេលរឿងរ៉ាវរបស់ពួកគេត្រូវគេដឹង រឿងនោះនឹងត្រូវនិយាយតពីមាត់មួយទៅមាត់មួយ។ ពេលត្រូវគេនិយាយ គេគិតថាការនិយាយរបស់ពួកគេនោះវាជារឿងធម្មតា... តែគេមិនយល់ពីអារម្មណ៍អាម៉ាស់ដែលមាននៅខាងក្នុងខ្លួនរបស់ក្មេងប្រុសនោះទេ។

ប្រហែលជាក្មេងប្រុសអាចនិយាយជាមួយមិត្តជិតស្និទ្ធដែលមានរឿងប្រហាក់ប្រហែលគ្នាបាន។ យើងអាចប្រាប់ទៅនរណាដែលគេមានការចេះដឹង តែអ្នកនោះមិនគួរយករឿងរបស់យើងទៅនិយាយតគ្នាក្នុង គោលបំណងសើចចំអក ឬលេងសើចឡើយ... ពួកគេគួរតែយល់ចិត្តយើង ហើយអាចឱ្យយោបល់ និងគំនិតដល់យើងដើម្បីជួយយើងដោះស្រាយបញ្ហា។ ពួកគេត្រូវតែជាអ្នកដែលគួរអោយទុកចិត្ត និងអាចរក្សា ការសម្ងាត់បាន... គ្រួសារត្រូវតែយល់ចិត្តយើង។ ការយល់ដឹងពិតជាសំខាន់ ហើយការ រក្សាការសម្ងាត់ ពិតជាសំខាន់ សំរាប់កុមារ។

យោងតាមគំនិតរបស់ខ្ញុំ ការរំលោភបំពានផ្លូវភេទអាចកើតឡើងគ្រប់ទីកន្លែង... យើងត្រូវការមនុស្សឱ្យជួយយើង ជួយអប់រំមនុស្ស អោយជៀសផុតពីការអូសទាញរបស់គេ ប្រសិនបើមានកន្លែងដែលត្រូវទៅ ន្លែងនោះគួរតែមានការ អប់រំ...គ្រប់កម្មវិធីទាំងអស់...

បុគ្គលិកត្រូវតែនិយាយជាមួយកុមារតាមបែបទន់ភ្លន់ពេលពួកគេធ្វើអ្វីមួយខុស កុំប្រើហិង្សា។ កុមារគួរតែត្រូវបានគេស្ដាប់ និងត្រូវបានពិចារណាក្នុងការសម្រេចចិត្ត។

ទាំងក្មេងប្រុសនិងក្មេងស្រីមានការឈឺចាប់ដូចគ្នា... ពួកគេមានគំនិត យោបល់ អារម្មណ៍ បេះដូង និងការឈឺចាប់។ កុំមើលងាយក្មេងប្រុសពេលពួកគេត្រូវគេរំលោភបំពានផ្លូវភេទ ពីព្រោះវាប៉ះពាល់អារម្មណ៍របស់ពួក គេ។

ខ្ញុំចង់សរសេរសៀវភៅ ដើម្បីធ្វើឱ្យគេគ្រប់គ្នាបានដឹងពីបទពិសោធន៍រងការរំលោភបំពានផ្លូវភេទរបស់ខ្ញុំ ហើយដើម្បីឱ្យគេយល់ពីមូលហេតុដែលនាំឱ្យក្មេងប្រុសអាម៉ាស់ខ្លាំង... ការបាត់បង់កិត្តិយស...ពួកគេត្រូវយល់ថាក្មេងប្រុស ក៏មានអ្វីៗទាំងនេះដែរ។ ដោយសារខ្ញុំគិតថា ការសិក្សាស្រាវជ្រាវនេះរក្សាការសម្ងាត់ឱ្យខ្ញុំ ទើបខ្ញុំនិយាយពីបញ្ហានេះ ខ្ញុំសូមអរគុណអង្គការ និងអ្នកដែលបានជួយក្មេងប្រុស។